វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

MIGHTY EARTH

SNR
可持续天然橡胶
Sustainable Natural Rubber


# គោលការណ៍ណែនាំ សម្រាប់ដំណាំកៅស៊ូធម្មជាតិ ដោយនិរន្តរភាព

ភ្នំពេញ ឆ្នាំ ២០១៩

# គោលការណ៍ណែនាំសម្រាប់ដំណាំកៅស៊ូធម្មជាតិដោយនិរន្តរភាព

Guidance for Sustainable Natural Rubber

中国五矿化工进出口商会

## សភាពាណិជ្ជកម្មចិនផ្នែកនាំចូល និងនាំចេញ
## លោហធាតុ រ៉ែ និងសារធាតុគីមី

China Chamber of Commerce of Metals,
Minerals & Chemicals Importers & Exporters

# មាតិកា


**មាតិកា** ........ 2

**បុព្វកថា** ........ 1

**ជំពូក ១. វិសាលភាព និងការអនុវត្ត** ........ 3

**ជំពូកទី ២. គោលការណ៍នាំមុខ** ........ 5

២.១ អនុលោមភាពចំពោះច្បាប់ និងប្រតិបត្តិការធុរកិច្ចស្របច្បាប់ ........ 5

២.២ គោរពសិទ្ធិមនុស្ស និងជានាសិទ្ធិ និងផលប្រយោជន៍ ........ 5

២.៣ ការគិតគូរដោយឡែកទៅតាមទីតាំងជាក់លាក់ជាមួយការគោរពភាពខុសគ្នា ........ 5

២.៤ ភាពប្រកួតប្រជែងដោយបើកចំហ តម្លាភាព និងត្រឹមត្រូវ ........ 6

២.៥ កិច្ចការពារបរិស្ថាន និងលក្ខខណ្ឌបៃតង និងផលប្រយោជន៍ខាងអេកូឡូស៊ី ........ 6

២.៦ ការអភិវឌ្ឍប្រែបនវានុវត្ត បរិយាប័ន្ន និងការចែករំលែក ........ 6

**ជំពូក ៣. ប្រព័ន្ធពិនិត្យពិច័យ និងការអនុវត្ត** ........ 7

៣.១ ប្រព័ន្ធពិនិត្យពិច័យ ........ 7

៣.១.១ គោលនយោបាយពិនិត្យពិច័យ ........ 7

៣.១.២ ក្របខ័ណ្ឌគ្រប់គ្រង ........ 7

៣.១.៣ កិច្ចសហការនៃអ្នកពាក់ព័ន្ធ ........ 8

៣.២ ការកំណត់អត្តសញ្ញាណ និងការវាយតម្លៃហានិភ័យ ........ 8

៣.២.១ ការវាយតម្លៃសាវតា ........ 8

៣.៣ ការទប់ស្កាត់ និងការកាត់បន្ថយហានិភ័យ ........ 9

៣.៣.១ ការគ្រប់គ្រងក្រោមការសម្របសម្រួល ........ 9

៣.៣.២ សកម្មភាពឆ្លើយតប ........ 9

៣.៤ ការអង្កេតដាន និងការរាយការណ៍ឲ្យមានប្រសិទ្ធភាព ........ 10

**ជំពូក ៤. ការវិនិយោគបឋម** ............ 12

**៤.១ បរិស្ថានសង្គម** ............ 12

៤.១.១ អភិបាលកិច្ចប្រទេស ............ 12

៤.១.២ អង្គការសង្គមស៊ីវិល ............ 13

៤.១.៣ ទំនាក់ទំនងសហគមន៍ ............ 13

**៤.២ កម្មសិទ្ធិដី** ............ 14

៤.២.១ ការបញ្ជាក់អំពីសិទ្ធិចំពោះដីធ្លី ............ 14

៤.២.២ ការទទួលបានសិទ្ធិចំពោះដីធ្លី ............ 14

៤.២.៣ ការផ្ទេរដីធ្លី និងការស្តារឡើងវិញ ............ 15

**៤.៣ បរិស្ថានធម្មជាតិ** ............ 15

៤.៣.១ ចំការកៅស៊ូ ............ 15

៤.៣.២ រោងចក្រកែច្នៃកៅស៊ូឆៅ ............ 17

**៤.៤ ស្ថិរភាពសេដ្ឋកិច្ច** ............ 17

៤.៤.១ បរិស្ថានសេដ្ឋកិច្ច ............ 17

៤.៤.២ បរិស្ថានទីផ្សារ ............ 18

៤.៤.៣ បរិស្ថានបច្ចេកទេស ............ 19

**ជំពូក ៥. ការគ្រប់គ្រងនិរន្តរភាព និងការត្រួតពិនិត្យហានិភ័យ នៅក្នុងប្រតិបត្តិការជំនួញ** ............ 20

**៥.១ ការទទួលខុសត្រូវសង្គម** ............ 20

៥.១.១ សិទ្ធិសហគមន៍ និងជនជាតិដើមភាគតិច ............ 20

៥.១.២ សិទ្ធិការងារ និងផលប្រយោជន៍ ............ 21

**៥.២ ការទទួលខុសត្រូវខាងបរិស្ថាន** ............ 22

៥.២.១ ចំការកៅស៊ូ ............ 22

៥.២.២ រោងចក្រកែច្នៃកៅស៊ូឆៅ ............ 23

៥.៣ ការទទួលខុសត្រូវខាងសេដ្ឋកិច្ច ........ 24
៥.៣.១ ការជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច ........ 24
៥.៣.២ ការរក្សាទម្លាប់ល្អក្នុងធុរកិច្ច ........ 25
៥.៣.៣ ការបង់ និងទទួលពន្ធ និងអាករនានាស្របតាមច្បាប់ ........ 25
**ឧបសម្ព័ន្ធ** ........ 26
ឧបសម្ព័ន្ធ ១. អ្នកដែលបានរួមវិភាគទានចំពោះគោលការណ៍ណែនាំនេះ ........ 26
ឧបសម្ព័ន្ធ ២. បច្ចេកស័ព្ទ និងនិយមន័យ ........ 27
ឧបសម្ព័ន្ធ ៣. ឯកសារយោង អនុសញ្ញាអន្តរជាតិ និងស្តង់ដារពាក់ព័ន្ធនានា........ 33
ឧបសម្ព័ន្ធ ៤. សេចក្តីថ្លែងអំណរគុណ ........ 37

# បុព្វកថា

ក្នុងនាមជាវត្ថុធាតុដើមគន្លឹះមួយក្នុងឧស្សាហកម្មដែលមានសារៈសំខាន់ជាយុទ្ធសាស្ត្រ ក៏ដូចជាដំណាំកសិកម្ម និងដំណាំព្រៃឈើដែលមានតម្លៃសេដ្ឋកិច្ចផងដែរ ដំណាំកៅស៊ូមានប្រយោជន៍សម្រាប់ការប្រើប្រាស់ច្រើនយ៉ាង ក្រោមរូបភាពជាដំណាំកសិកម្ម ប្រភេទឈើសម្រាប់ការផលិតឈើ និងផលិតផលឧស្សាហកម្ម និងអនុផលដទៃទៀតសម្រាប់ផ្តល់ចំណូលហិរញ្ញវត្ថុ នៅក្នុងវដ្តទាំងមូលនៃអាយុកាលរបស់ដំណាំនេះ និងខ្សែចង្វាក់តម្លៃក្នុងឧស្សាហកម្ម។ វាដើរតួសំខាន់មួយនៅក្នុងការកែលំអរបរចិញ្ចឹមជីវិត និងក្នុងការលើកកំពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ ការអភិវឌ្ឍឆាប់រហ័សនៃសេដ្ឋកិច្ចពិភពលោក បានរួមចំណែកក្នុងការធ្វើឲ្យមានកំណើនតម្រូវការកៅស៊ូធម្មជាតិ ដែលនាំទៅរកការបន្តពង្រីកចំការដំណាំកៅស៊ូធម្មជាតិ។

ទោះជាយ៉ាងណាក៏ដោយ ដំណាំកៅស៊ូបែបឯកវប្បកម្ម រួមផ្សំជាមួយពិពិធកម្មការវិនិយោគលើដំណាំកៅស៊ូធម្មជាតិ បាននាំឲ្យមានបញ្ហាបរិស្ថាន និងសង្គមមួយចំនួន។ ដូច្នេះ ប្រការសំខាន់គឺអ្នកផលិតកៅស៊ូធម្មជាតិត្រូវបង្កើនការយល់ដឹង និងសមត្ថភាពគ្រប់គ្រងរបស់ខ្លួន (ជាពិសេសនៅក្នុងដំណាក់កាលដាំ និងកែច្នៃ) នៃការវិនិយោគ និងការបង្កើតម៉ូដែលឧស្សាហកម្ម ការគ្រប់គ្រងហានិភ័យ ការអភិវឌ្ឍដោយនិរន្តរភាព និងប្រព័ន្ធពិនិត្យពិច័យ ដើម្បីទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើសង្គម បរិស្ថាន និងសេដ្ឋកិច្ច នៃប្រទេសម្ចាស់ផ្ទះ និងពង្រឹងជាបន្ថែមទៀតនូវកិច្ចសហការ ការអភិវឌ្ឍរួមគ្នា និងការចែករំលែកជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីជួយការពារសុវត្ថិភាព និងនិរន្តរភាពឧស្សាហកម្មនេះ។

ឯកសារណែនាំសម្រាប់ដំណាំកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាពនេះ (ដែលចាប់ពីនេះតទៅហៅថាឯកសារណែនាំ) ផ្តោតលើហានិភ័យ។ គោលការណ៍នាំមុខ គឺលើកទឹកចិត្តឲ្យមានការអភិវឌ្ឍជាបរិយាប័ន្ន ដើម្បីឈានទៅរកស្ថានភាពឈ្នះ-ឈ្នះ និង ធ្វើឲ្យមានការបើកចំហ និងតម្លាភាព។ ឯកសារណែនាំនេះមានគោលដៅផ្តល់ឲ្យប្រតិបត្តិករនៅក្នុងការវិនិយោគលើដំណាំកៅស៊ូធម្មជាតិ ការដាំ និងការកែច្នៃនូវគោលនយោបាយធុរកិច្ច ក្របខ័ណ្ឌគ្រប់គ្រង ការវិភាគហានិភ័យ ទិន្នន័យយោងនៃការវាយតម្លៃ និងការអនុវត្តវិធី សម្រាប់កំណត់អត្តសញ្ញាណ ការទប់ស្កាត់ និងការគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធ ដើម្បីអាចជួយពួកគេ ក្នុងការបញ្ចូលប្រព័ន្ធពិនិត្យពិច័យដែលផ្តោតលើហានិភ័យ ទៅក្នុងសកម្មភាពគ្រប់គ្រងប្រចាំថ្ងៃរបស់ពួកគេ និងសម្រេចបានអនុលោមភាពនៃធុរកិច្ច និងការអភិវឌ្ឍដោយចីរភាព។

ការស្រាវជ្រាវ និងការរៀបចំឯកសារណែនាំនេះ បានធ្វើឡើងដោយសភាពាណិជ្ជកម្មចិនផ្នែកនាំចូល និងនាំចេញលោហធាតុ រ៉ែ និងសារធាតុគីមី នៅក្រោមកិច្ចសហការចិន-ចក្រភពអង់គ្លេសលើកម្មវិធីវិនិយោគ និងពាណិជ្ជកម្មអន្តរជាតិព្រៃឈើ (InFIT) ដែលឧបត្ថម្ភដោយ ក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋ

ប្រជាមានិតចិន រដ្ឋបាលព្រៃឈើរដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន និងក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស។ ឯកសារណែនាំនេះ យោងទៅរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាព អនុសញ្ញាស្តីពីជីវចម្រុះ គោលការណ៍នាំមុខរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស នៃអង្គការបមាណីយកម្មអន្តរជាតិ គោលការណ៍ណែនាំ ISO 26000 ស្តីពី ការទទួលខុសត្រូវសង្គម និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធដទៃទៀត កិច្ចផ្តួចផ្តើម និងឯកសារស្តីពីការទទួលខុសត្រូវសង្គម។ តំណាងពីវិទ្យាស្ថានស្រាវជ្រាវនិងរចនាបថឧស្សាហកម្មកៅស៊ូនៃទីក្រុងប៉េកាំង វិទ្យាស្ថានរុក្ខសាស្ត្រនៅគុនមីង(សភាវិទ្យាសាស្ត្រចិន) មជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោក ក្រុមប្រឹក្សាជាតិវាយនភណ្ឌ និងសម្ភារៈតែងកាយចិន សកលវិទ្យាល័យធុរកិច្ចនិងសេដ្ឋកិច្ចអន្តរជាតិ សភាវិទ្យាសាស្ត្រកសិកម្មត្រូពិកនៃប្រទេសចិន SynTao អង្គការក្លូបលរីតណែស និងអង្គការដទៃទៀត ក៏ដូចជា ក្រុមដំណាំកៅស៊ូហៃណាន់ និងសហគ្រាសដទៃទៀត បានចូលរួមនៅក្នុងការស្រាវជ្រាវ ការបង្កើត និងការរៀបចំឯកសារណែនាំនេះផងដែរ។ សភាពាណិជ្ជកម្មចិននៃក្រុមហ៊ុននាំចូល និងនាំចេញលោហធាតុ រ៉ែ និងសារធាតុគីមី នឹងធ្វើបច្ចុប្បន្នភាព និងកែសម្រួលឯកសារណែនាំនេះ ទៅតាមករណីសមស្រប ជាការឆ្លើយនឹងការប្រើប្រាស់ឯកសារណែនាំនេះ និងតាមរយៈការពិគ្រោះយោបល់ពេញលេញជាមួយអ្នកពាក់ព័ន្ធនានា។

# ជំពូក ១. ទិសាលភាព និងការអនុវត្ត

ឯកសារណែនាំនេះ ពាក់ព័ន្ធជាចំបងចំពោះធុរកិច្ច ដែលវិនិយោគ ការដាំ ឬកែច្នៃកៅស៊ូធម្មជាតិ។ ឯកសារណែនាំនេះ ក៏អាចយកយកទៅប្រើប្រាស់ដោយសហគ្រាសនៅក្នុងសកម្មភាពដើមខ្សែ និងចុងខ្សែ និងអង្គការដទៃទៀត នៅក្នុងឧស្សាហកម្មកៅស៊ូធម្មជាតិ នៅក្នុងការគ្រប់គ្រងខ្សែចង្វាក់ផ្គត់ផ្គង់របស់ពួកគេផងដែរ។ អង្គការដឹកនាំនិងវិទ្យាស្ថានហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធដទៃទៀត ក៏អាចប្រើប្រាស់ឯកសារណែនាំនេះផងដែរ ទន្ទឹមនឹងធ្វើការសម្រេចលើការផ្តល់ហិរញ្ញប្បទាន និងការសម្រេចលើការដឹកនាំ ដែលទាក់ទងនឹងឧស្សាហកម្មកៅស៊ូធម្មជាតិ។ ឯកសារណែនាំនេះសម្រាប់ការប្រើប្រាស់ដោយស្ម័គ្រចិត្ត។ អ្នកប្រើប្រាស់អាចប្រើប្រាស់ឯកសារនេះដាច់ដោយឡែក ឬជាមួយឯកសារពាក់ព័ន្ធដទៃទៀត។

អ្នកប្រើប្រាស់អាចពិគ្រោះឯកសារណែនាំនេះ នៅក្នុងពេលសិក្សាបឋម និងក្នុងដំណាក់កាលដំបូងៗ នៃការធ្វើសេចក្តីសម្រេចលើការវិនិយោគ ដើម្បីកំណត់អត្តសញ្ញាណ និងវាយតម្លៃអនុលោមភាព និងហានិភ័យនិរន្តរភាព និងកាលានុវត្តភាពនៃគម្រោងឧស្សាហកម្មកៅស៊ូធម្មជាតិ និងដើម្បីនដាក់បញ្ចូលលទ្ធផលនៃការវាយតម្លៃទៅក្នុងការធ្វើសេចក្តីសម្រេច និងការរៀបចំការអនុវត្តការវិនិយោគគម្រោង។ តាមរយៈការពិគ្រោះឯកសារណែនាំនេះនៅក្នុងដំណាក់កាលដំបូងៗ អ្នកជំនួញនានាអាចកំណត់អត្តសញ្ញាណ ប៉ាន់ប្រមាណ និងគ្រប់គ្រងវិធីនានានៃប្រតិបត្តិការប្រកបដោយការទទួលខុសត្រូវ និងបញ្ចូលហានិភ័យនៃនិរន្តរភាព និងកាលានុវត្តភាព ទៅក្នុងការរៀបចំផែនការវិនិយោគរបស់អ្នក ការសិក្សាលទ្ធភាព ការពិនិត្យពិច័យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ការបង្កើតរចនាបថ និងការរៀបចំផែនការអនុវត្ត និងការជ្រើសរើសដៃគូសហការ។ល។ ស្របតាមអនុសាសន៍ដែលមាននៅក្នុងឯកសារណែនាំនេះ។

ឯកសារណែនាំនេះ អាចជួយសហគ្រាសនានាក្នុងការបង្កើតគោលនយោបាយ និងគោលការណ៍ណែនាំ ការប្រាស្រ័យទាក់ទង និងសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធនានា និងទទួលស្គាល់ និងឆ្លើយតបទៅនឹងកាលានុវត្តភាព និងហានិភ័យ។

អ្នកប្រើប្រាស់ក៏អាចប្រើប្រាស់ឯកសារណែនាំនេះ នៅក្នុងពេលអនុវត្ត និងប្រតិបត្តិការគម្រោងវិនិយោគកៅស៊ូធម្មជាតិ ការដាំ និងការកែច្នៃផងដែរ ដើម្បីកំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យ និងកាលានុវត្តិភាពនៃប្រតិបត្តិការ និងនិរន្តរភាពនៃគម្រោងឧស្សាហកម្មកៅស៊ូធម្មជាតិ និងបញ្ចូលលទ្ធផលនៃការវាយតម្លៃទៅក្នុងការគ្រប់គ្រងលើការអនុវត្ត និងប្រតិបត្តិការគម្រោង ដែលរួមទាំង ការកែតម្រូវចាំបាច់លើផ្នែកពាក់ព័ន្ធនានា និងដំណើរការនៃគម្រោងនានា ដូចមានណែនាំក្នុងឯកសារណែនាំនេះ។

អ្នកប្រើប្រាស់ក៏អាចបង្កើត និងកែលំអរចនាសម្ព័ន្ធចាត់ចែង និងប្រព័ន្ធគ្រប់គ្រងរបស់ខ្លួនផងដែរ

ដោយប្រើប្រាស់ឯកសារណែនាំនេះសម្រាប់បង្កើនការយល់ដឹងនិងសមត្ថភាពរបស់បុគ្គលិកពាក់ព័ន្ធ ដើម្បីឆ្លើយតបនឹងហានិភ័យ និងកាលានុវត្តិភាព ដែលរួមទាំង ការវាយតម្លៃគុណផល ដែលទាក់ទងនឹងការទប់ស្កាត់ហានិភ័យ និងការឆ្លើយតបនឹងកាលានុវត្តិភាព។

## ជំពូកទី ២. គោលការណ៍នាំមុខ

ការអភិវឌ្ឍខ្សែចង្វាក់ឧស្សាហកម្មកៅស៊ូធម្មជាតិ គួរតែគោរពតាមទស្សនៈ"នវានុវត្តន៍ ការសម្របសម្រួល ការធ្វើឲ្យបៃតង ការបើកចំហ និងការចែករំលែក" និងប្ដេជ្ញាសម្រេចបានរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាព និងគោលដៅអភិវឌ្ឍន៍ដោយចីរភាពនៃអង្គការសហប្រជាជាតិ (SDGs) តាមរយៈកិច្ចសហប្រតិបត្តិការពីអ្នកពាក់ព័ន្ធនានា នៅតាមខ្សែចង្វាក់ឧស្សាហកម្មនេះ។ ការអភិវឌ្ឍដោយចីរភាពដំណាំកៅស៊ូធម្មជាតិ ត្រូវគោរពតាមគោលការណ៍នាំមុខចំនួនប្រាំមួយដូចតទៅ។

### ២.១ អនុលោមភាពចំពោះច្បាប់ និងប្រតិបត្តិការធុរកិច្ចស្របច្បាប់

គួរគោរពតាមច្បាប់ និងបទបញ្ញត្តិនានាទាំងអស់នៃប្រទេសនោះ។ ការគោរពក្រមអនុវត្តអន្តរជាតិដែលពាក់ព័ន្ធ ដែលរួមទាំង គោលការណ៍នានាដែលមានចែង ប៉ុន្តែមិនកំហិតត្រឹមច្បាប់អន្តរជាតិ អនុសញ្ញាអន្តរជាតិ និងប្រពៃណីជាអន្តរជាតិឡើយ។ គួរគោរពគោលការណ៍ប្រតិបត្តិការធុរកិច្ចស្របច្បាប់។

### ២.២ គោរពសិទ្ធិមនុស្ស និងធានាសិទ្ធិ និងផលប្រយោជន៍

គួរកំណត់អត្តសញ្ញាណ និងវាយតម្លៃឲ្យបានពេញលេញនូវផលប៉ះពាល់ផ្ទាល់ និងប្រយោលនៃការអនុវត្តក្នុងធុរកិច្ច មកលើសិទ្ធិមនុស្ស និងប្រកាន់យកវិធានការសមស្របសម្រាប់បង្ការទុកជាមុន ដើម្បីទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច បុគ្គលិក និងអ្នកពាក់ព័ន្ធដទៃទៀត។ គួរការពារសិទ្ធិមនុស្ស និងផលប្រយោជន៍ការងារប្រកបដោយប្រសិទ្ធភាព ដើម្បីលើកកំពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

### ២.៣ ការគិតគូរដោយឡែកទៅតាមទីតាំងជាក់លាក់ជាមួយការគោរពភាពខុសគ្នា

ក្នុងពេលធ្វើការសម្រេចលើការវិនិយោគ ឬ នៅក្នុងអំឡុងពេលនៃប្រតិបត្តិការធុរកិច្ចប្រចាំថ្ងៃ គួរពិចារណាឲ្យបានពេញលេញនូវបរិស្ថានធម្មជាតិ (ដែលរួមទាំង ប៉ុន្តែមិនកំហិតត្រឹម អាកាសធាតុ ដី ព្រៃ សត្វព្រៃ និងជលសាស្ត្រ) ភាពសមស្របនៃបរិស្ថានទាំងនោះ ត្រូវកំណត់អត្តសញ្ញាណ និងវាយតម្លៃទិដ្ឋភាពដែលពាក់ព័ន្ធនានានៃបរិស្ថានសង្គម (ដូចជា នយោបាយក្នុងមូលដ្ឋាន លិខិតបទដ្ឋានគតិយុត្តិ វប្បធម៌ សាសនា និងប្រពៃណី) និងប៉ាន់ប្រមាណកម្រិតបន្សាំបានរបស់វិនិយោគិន ចំពោះបរិបទសង្គម នៃប្រទេសជាម្ចាស់ផ្ទះ។

## ២.៤ ភាពប្រកួតប្រជែងដោយបើកចំហ តម្លាភាព និងត្រឹមត្រូវ

ធ្វើការបើកចំហភ្លាមៗនូវការសម្រេចរបស់ខ្លួន និងសកម្មភាពដែលមានផលប៉ះពាល់មកលើសេដ្ឋកិច្ច សង្គម និងបរិស្ថាន និងបង្ហាញឲ្យដឹងពីកម្រិតនៃផលប៉ះពាល់ដែលអាចកើតមាន។ គួររក្សាការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់។ គួរចូលរួមនៅក្នុងការប្រកួតប្រជែងទីផ្សារដោយសកម្ម តាមគោលការណ៍ត្រឹមត្រូវ និងស្មើភាព តាមរយៈប្រតិបត្តិការធុរកិច្ចដោយស្មោះត្រង់។ មិនត្រូវចូលរួមក្នុងសកម្មភាពពុករលួយណាមួយឡើយ។ គួររក្សាលក្ខខណ្ឌទីផ្សារត្រឹមត្រូវ និងទម្លាប់អនុវត្តល្អ។

## ២.៥ កិច្ចការពារបរិស្ថាន និងលក្ខខណ្ឌបៃតង និងផលប្រយោជន៍ខាងអេកូឡូស៊ី

គួរកំណត់អត្តសញ្ញាណផលប៉ះពាល់បរិស្ថានដែលអាចមាននៃការអនុវត្តក្នុងធុរកិច្ច គួរចាត់វិធានការដើម្បីទប់ស្កាត់ ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន អាកាសធាតុ និងជីវចម្រុះ និងសម្រេចឲ្យបាននូវការអភិវឌ្ឍដែលមានសុខុដុម្មនីយកម្ម នៃផលប្រយោជន៍ខាងអេកូឡូស៊ី និងសេដ្ឋកិច្ចតាមរយៈសកម្មភាពនានា ដូចជា កសិកម្មចម្រុះ និងប្រតិបត្តិការច្រើនមុខ។

## ២.៦ ការអភិវឌ្ឍបែបនវានុវត្ត បរិយាប័ន្ន និងការចែករំលែក

គួរពិចារណា និងគោរពផលប្រយោជន៍របស់អ្នកពាក់ព័ន្ធនានា ដែលរួមទាំង អាជ្ញាធរមូលដ្ឋាន សហគមន៍មូលដ្ឋាន និយោជិត និងសហគ្រាសទាំងនៅដើមខ្សែ និងចុងខ្សែនៃផលិតកម្ម។ គួរផ្តល់យោបល់តបយ៉ាងមានប្រសិទ្ធភាព ដល់អ្នកពាក់ព័ន្ធនានា អំពីកង្វល់ និងការតវ៉ាលើទិដ្ឋភាពសង្គមរបស់ពួកគេ។ គួរផ្តួចផ្តើមបែបបច្ចេកប្រឌិតឲ្យមានប្រព័ន្ធដំណាំ បច្ចេកវិទ្យាកែច្នៃ និងគំរូឧស្សាហកម្ម និងចែករំលែកការទទួលខុសត្រូវ និងគុណតម្លៃជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីសម្រេចបានការអភិវឌ្ឍជាបរិយាប័ន្ន។

# ជំពូក ៣. ប្រព័ន្ធពិនិត្យពិច័យ និងការអនុវត្ត

ផ្នែកនេះមានគោលដៅជួយសហគ្រាស ក្នុងការបង្កើតក្របខ័ណ្ឌ និងនីតិវិធីគ្រប់គ្រងហានិភ័យ។ គោលការណ៍ណែនាំដែលពាក់ព័ន្ធមានផ្តល់ជូនសម្រាប់បញ្ចូលប្រព័ន្ធពិនិត្យពិច័យដែលផ្អែកលើហានិភ័យ ទៅក្នុងប្រតិបត្តិការប្រចាំថ្ងៃ ដែលរួមទាំងការវាយតម្លៃផលប៉ះពាល់ជាក់ស្តែង និងដែលអាចមានមកលើអ្នកពាក់ព័ន្ធនានា និងការអភិវឌ្ឍដោយចីរភាព ដោយសារតែការវិនិយោគលើកៅស៊ូធម្មជាតិ ចំការដំណាំ និងដំណើរការ ក៏ដូចជា សកម្មភាពអនុវត្តដទៃទៀតផងដែរ ដើម្បីបញ្ចូលលទ្ធផលនៃការវាយតម្លៃ ទៅក្នុងប្រព័ន្ធគ្រប់គ្រង ដើម្បីរៀបចំវិធានការតបនិងចំណាត់ការ ដើម្បីអង្កេតដានប្រសិទ្ធភាពនៃវិធានការដែលប្រកាន់យក និងដើម្បីរាយការណ៍ពីវឌ្ឍនភាពនៅក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននានា។

## ៣.១ ប្រព័ន្ធពិនិត្យពិច័យ

### ៣.១.១ គោលនយោបាយពិនិត្យពិច័យ

៣.១.១.១ គោលនយោបាយពិនិត្យពិច័យមួយ គួរតែបានរៀបចំឡើង ដាក់ឲ្យអនុវត្ត និងអភិវឌ្ឍ ឲ្យស្របគ្នាជាមួយសំណុំលក្ខណៈនៃធុរកិច្ច ផលិតផល ឬសេវា របស់សហគ្រាសផ្ទាល់ និងផ្អែកលើផលប៉ះពាល់ជាក់ស្តែង និងដែលអាចមាន មកលើអ្នកពាក់ព័ន្ធនានា និងការអភិវឌ្ឍដោយចីរភាព។ ការប្តេជ្ញា ក្នុងការកំណត់អត្តសញ្ញាណ បញ្ចៀស និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលកើតឡើងនៅក្នុងការអនុវត្តធុរកិច្ច នៅក្នុងអំឡុងពេលនៃការវិនិយោគលើកៅស៊ូធម្មជាតិ និងបង្កើតចំការដំណាំកៅស៊ូ និងការកែច្នៃ ត្រូវតែមានចែងច្បាស់នៅក្នុងគោលនយោបាយនេះ។

៣.១.១.២ គោលនយោបាយពិនិត្យពិច័យ គួរតែចែងច្បាស់ថា ការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវ គឺជាគោលដៅត្រូវសម្រេចឲ្យបានជាបន្តបន្ទាប់ និងរស់រវើក ដែលជាការឆ្លើយតបនឹងហានិភ័យនានាដែលអាចកើតមាន ជាលទ្ធផលនៃការកែប្រែលើការអនុវត្តនៅក្នុងធុរកិច្ច និងការគ្រប់គ្រងសហគ្រាស។

៣.១.១.៣ គោលនយោបាយពិនិត្យពិច័យ គួរតែត្រូវបានផ្សព្វផ្សាយដល់និយោជិត អតិថិជន និងអ្នកផ្គត់ផ្គង់ និងគួរតែអាចឲ្យសាធារណជន និងអ្នកពាក់ព័ន្ធដទៃទៀតបានដឹងផងដែរ។

៣.១.១.៤ គោលនយោបាយពិនិត្យពិច័យ គួរតែផ្តល់ស្តង់ដារ ឬឯកសារនានា ដូចជា គោលការណ៍ណែនាំសម្រាប់អនុវត្តតាម ឬជាឯកសារយោង សម្រាប់ការគ្រប់គ្រងការងារពិនិត្យពិច័យ។

### ៣.១.២ ក្របខណ្ឌគ្រប់គ្រង

៣.១.២.១ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងសមស្របមួយ គួរតែបានបង្កើតឡើង ដើម្បីធានាថា គោលនយោបាយពិនិត្យពិច័យត្រូវបានដាក់បញ្ចូលយ៉ាងមានប្រសិទ្ធភាពទៅក្នុងដំណើរការគ្រប់គ្រង។

៣.១.២.២ វិធានពិនិត្យពិច័យ គួរតែបានដាក់បញ្ចូលទៅក្នុងដំណើរការនៃការគ្រប់គ្រង និងការសម្របសម្រួលរវាងនាយកដ្ឋាននានា ក្នុងចំណោមផ្នែកខុសៗគ្នានៃធុរកិច្ច ជាពិសេស ក្នុងករណីដែលការលើកទឹកចិត្តសម្រាប់ផ្នែកនោះនៃធុរកិច្ច អាចមានទំនាស់ជាមួយការអភិវឌ្ឍដោយចីរភាព និងគោលនយោបាយពិនិត្យពិច័យនៃសហគ្រាសនោះ។

៣.១.២.៣ យន្តការបណ្តឹងសារទុក្ខនៅលំដាប់ថ្នាក់សមស្រប គួរតែបានបង្កើតឡើង ជាមួយសហគមន៍មូលដ្ឋាន ដោយផ្តោតលើផលប៉ះពាល់នៃការអនុវត្តនៃធុរកិច្ចនោះ នៅក្នុងអំឡុងពេលវិនិយោគលើកៅស៊ូធម្មជាតិ ការអភិវឌ្ឍចំការកៅស៊ូ និងការកែច្នៃ។ យន្តការឧស្សាហកម្មដែលពាក់ព័ន្ធ គួរតែបានដាក់បញ្ចូលដើម្បីគូសបញ្ជាក់ និងកែលំអប្រព័ន្ធអង្កេតដានហានិភ័យ។

### ៣.១.៣ កិច្ចសហការនៃអ្នកពាក់ព័ន្ធ

៣.១.៣.១ ប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងយន្តការប្រាស្រ័យទាក់ទងមួយសម្រាប់ការពិនិត្យពិច័យ និងការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវ ដែលរួមទាំង ប្រព័ន្ធសម្របសម្រួលចាំបាច់សម្រាប់ការទទួលផល គួរតែបានបង្កើតឡើង ដើម្បីកែលំអភាពបំពេញគ្នានៃកិច្ចសហការ ជាមួយអ្នកពាក់ព័ន្ធនានា នៅក្នុងការបញ្ចៀស និងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន។

៣.២.៣.២ វិធានការទប់ស្កាត់ហានិភ័យ គួរតែបានបង្កើតឡើង នៅក្នុងទំនាក់ទំនងជាមួយដៃគូធុរកិច្ច និងអ្នកពាក់ព័ន្ធនានា។ លក្ខខណ្ឌតម្រូវ និងការរំពឹងទុករបស់អ្នកផ្គត់ផ្គង់ និងដៃគូនានា ដែលទាក់ទងនឹង ការអភិវឌ្ឍដោយចីរភាព គួរតែបានបញ្ជាក់នៅក្នុងកិច្ចសន្យាធុរកិច្ច និង/ឬ កិច្ចព្រមព្រៀងជាលាយលក្ខអក្សរ។

## ៣.២ ការកំណត់អត្តសញ្ញាណ និងការវាយតម្លៃហានិភ័យ

### ៣.២.១ ការវាយតម្លៃសាវតា

៣.២.១.១ គ្រប់កត្តាផ្ទៃក្នុង និងកត្តាខាងក្រៅទាំងវិជ្ជមាន និងអវិជ្ជមាន ដែលអាចប៉ះពាល់ ឬ រងការប៉ះពាល់ដោយសារដំណើរការនៃការវិនិយោគលើកៅស៊ូធម្មជាតិ ចំការកៅស៊ូ និងការកែច្នៃ គួរតែបានកំណត់អត្តសញ្ញាណ និងឲ្យនិយមន័យច្បាស់លាស់។

៣.២.១.២ អ្នកពាក់ព័ន្ធនានាដែលចូលរួមនៅក្នុងការពិនិត្យពិច័យ និងការទទួលខុសត្រូវ ក៏ដូចជាតម្រូវការ និងការរំពឹងទុកនានា ជាពិសេស ដែលទាក់ទងនឹងលក្ខខណ្ឌតម្រូវឲ្យមានអនុលោមភាព ក៏គួរតែបានកំណត់ និងឲ្យនិយមន័យច្បាស់សាស់ផងដែរ។

ការកំណត់អត្តសញ្ញាណហានិភ័យ

៣.២.២.១ ផលប៉ះពាល់អវិជ្ជមានជាក់ស្តែង ឬដែលអាចកើតមាន និងការប្រកាសគេរវសញ្ញា ដែលទាក់

ទងនឹងផលិតផល សេវាកម្ម និងទំនាក់ទំនងរបស់សហគ្រាសផ្ទាល់ គួរតែបានកំណត់អត្តសញ្ញាណ និងគួរតែបានវាយតម្លៃភាពរនីយភាព និងកម្រិតធ្ងន់ធ្ងរនៃហានិភ័យទាំងនោះផងដែរ។

៣.២.២.២ ការចាត់ថែងគួរតែធ្វើឲ្យបានច្បាស់ ទោះបីមានបំណងអនុវត្តការវាយតម្លៃហានិភ័យនៅនឹងកន្លែងដោយផ្ទាល់របស់ខ្លួន/នៅពេលណាព្យាយាមធ្វើឲ្យអ្នកជំនាញផ្ទៃក្នុង និង/ឬអ្នកជំនាញ ឬស្ថាប័នឯករាជ្យខាងក្រៅបានចូលរួម។

៣.២.២.៣ ក្រុមដែលអាចជាអ្នករងការប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀត គួរតែបានពិគ្រោះយោបល់ ទៅតាមករណីសមស្រប ដោយធ្វើការពិចារណាអំពីប្រភេទ និងបរិបទនៃការវិនិយោគលើកៅស៊ូធម្មជាតិ សកម្មភាពចំការកៅស៊ូ និងសកម្មភាពកែច្នៃ។

៣.២.២.៤ ការកំណត់អត្តសញ្ញាណហានិភ័យ និងការវាយតម្លៃផលប៉ះពាល់ គួរតែបានអនុវត្តជាទៀងទាត់ ជាពិសេស នៅមុនការប្រកាសចាប់ផ្តើមសកម្មភាពថ្មីៗ ឬ ទំនាក់ទំនងនានា និងការធ្វើសេចក្តីសម្រេចចំបងៗអំពីធុរកិច្ច ឬការកែប្រែនានា (ដូចជា ការចូលក្នុងទីផ្សារថ្មី ការធ្វើលទ្ធកម្មដីធ្លីនៅកន្លែងថ្មី ការបញ្ចូលផលិតផល ឬសេវាកម្មថ្មីៗ ការកែប្រែគោលនយោបាយ។ល។) ឬ នៅពេលឆ្លើយតបនឹង ឬ ព្យាករណ៍ការប្រែប្រួលនៅក្នុងបរិយាកាសធុរកិច្ច (ដូចជា កំណើនភាពតានតឹងក្នុងសង្គម)។

## ៣.៣ ការទប់ស្កាត់ និងការកាត់បន្ថយហានិភ័យ

### ៣.៣.១ ការគ្រប់គ្រងក្រោមការសម្របសម្រួល

៣.៣.១.១ គណនេយ្យភាព និងនីតិវិធីផ្ទៃក្នុងដែលពាក់ព័ន្ធគួរតែបានសម្របសម្រួល ដើម្បីបញ្ចូលលទ្ធផលនៃការវាយតម្លៃហានិភ័យ ទៅក្នុងអង្គភាពទាំងមូល ក្រោមទម្រង់ដែលមានសុខុដុម្មនីយកម្ម។ ផែនការគ្រប់គ្រងហានិភ័យ គួតែបានបង្កើតឡើង និងអនុវត្ត ដើម្បីទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន។

៣.៣.១.២ បុគ្គលិកគ្រប់គ្រងជាន់ខ្ពស់ គួរតែរ៉ាប់រងការទទួលខុសត្រូវលើការលុបបំបាត់ផលប៉ះពាល់បែបនេះ និងគួរធានាថា ការគ្រប់គ្រងរបស់ពួកគេ មានប្រសិទ្ធភាព តាមរយៈការធ្វើសេចក្តីសម្រេចផ្ទៃក្នុងឲ្យបានសមស្រប ការផ្តល់ថវិកា និងការតាមដានសមស្រប។

### ៣.៣.២ សកម្មភាពឆ្លើយតប

៣.៣.២.១ បន្ទាប់ពីបញ្ចូលលទ្ធផលនៃការវាយតម្លៃហានិភ័យដែលទាក់ទងនឹងការវិនិយោគលើកៅស៊ូធម្មជាតិ ចំការកៅស៊ូ និងការកែច្នៃ ទៅក្នុងដំណើរការគ្រប់គ្រង គួរចាត់វិធានការសមស្របដើម្បីដោះស្រាយហានិភ័យ។

៣.៣.២.២ ការអនុវត្តចំណាត់ការដាក់លាក់ អាស្រ័យលើថាតើសហគ្រាស/អង្គភាពបង្ក ឬ រួមចំណែកធ្វើ

ឲ្យមានផលប៉ះពាល់អវិជ្ជមានទាំងនោះឬទេ ឬថាតើវាមានការទាក់ទងផ្ទាល់ទៅនឹងផលិតផល ឬសេវាកម្មរបស់ខ្លួន តាមរយៈទំនាក់ទំនងធុរកិច្ចរបស់ខ្លួនឬទេ។ វាក៏អាស្រ័យផងដែរលើកិច្ចប្រឹងប្រែងរបស់សហគ្រាស/អង្គការ និងការវាយតម្លៃផលប៉ះពាល់ទាំងនេះមកលើភាគីនានាដែលពាក់ព័ន្ធនៅក្នុងការលប់បំបាត់ហានិភ័យទាំងនេះ។

៣.៣.២.៣ ក្នុងករណីដែលអត្តសញ្ញាណហានិភ័យដែលមានកំណត់មានលក្ខណៈប្រយោល សហគ្រាសនោះ គួរមានឥទ្ធិពលមកលើសហគ្រាសដទៃ នៅក្នុងការបញ្ចៀស ឬកាត់បន្ថយហានិភ័យដែលបានកំណត់ឃើញនោះ ប្រសិនបើអាចធ្វើបាន។ នៅពេលដែលសហគ្រាសខ្វះកិច្ចប្រឹងប្រែងបែបនេះ និងមិនអាចកាត់បន្ថយហានិភ័យប្រយោលនេះ សហគ្រាសគួរពិចារណាជម្រើសផ្សេងទៀតសម្រាប់កាត់បន្ថយហានិភ័យនោះ ដែលរួមទាំងថាតើ ត្រូវបញ្ចប់ធុរកិច្ចដែលមានហានិភ័យនោះឬយ៉ាងណា និងត្រូវវាយតម្លៃផលប៉ះពាក់ដែលអាចកើតចេញពីការធ្វើបែបនោះផងដែរ។

## ៣.៤ ការអង្កេតដាន និងការរាយការណ៍ឲ្យមានប្រសិទ្ធភាព

៣.៤.១.១ គួរអង្កេតមើលប្រសិទ្ធភាពនៃសកម្មភាព និងវិធានការនានា ដែលបានអនុវត្ត ដើម្បីផ្ទៀងផ្ទាត់ថាតើបានកាត់បន្ថយ ឬលុបបំបាត់ហានិភ័យដែរឬទេ។

៣.៤.១.២ ការអង្កេតដានដែលមានប្រសិទ្ធភាព គួរតែបានធ្វើឡើងជាមួយសូចនាករបរិមាណ និងគុណភាពសមស្រប និងគួរតែគិតបញ្ចូលផងដែរនូវយោបល់ទាំងពីផ្ទៃក្នុង និងពីអ្នកខាងក្រៅ ដែលរួមទាំងអ្នកដែលស្ថិតក្នុងចំណោមក្រុមជនរងគ្រោះផងដែរ។

៣.៤.១.៣ ការវាយតម្លៃបន្ថែម អាចចាំបាច់សម្រាប់ហានិភ័យដែលត្រូវការឲ្យមានការកាត់បន្ថយ នៅពេលដែលស្ថានភាពប្រែប្រួល។

៣.៤.២ ការរាយការណ៍អំពីវឌ្ឍនភាព

៣.៤.២.១ គោលនយោបាយពិនិត្យពិច័យ និងការអនុវត្តដែលពាក់ព័ន្ធ គួរតែបានរាយការណ៍ ទៅអ្នកពាក់ព័ន្ធនានា ដែលរួមទាំង ហានិភ័យដែលបានកំណត់អត្តសញ្ញាណ និងវិធានការនានាដែលបានអនុវត្តដើម្បីកាត់បន្ថយហានិភ័យទាំងនោះ។ ដោយឡែក នៅពេលអ្នកពាក់ព័ន្ធជាក្រុមជនរងគ្រោះលើកស្នើលក្ខខណ្ឌតម្រូវ ឬមានកង្វល់ រាល់របាយការណ៍អំពីរបៀបដោះស្រាយផលប៉ះពាល់អវិជ្ជមានដែលពាក់ព័ន្ធក៏គួរតែបានផ្ដល់ឲ្យផងដែរ។

៣.៤.២.២ របាយការណ៍នេះគួរផ្ដល់ព័ត៌មានគ្រប់គ្រាន់ តាមទម្រង់ដែលក្រុមគោលដៅ និងបុគ្គលជាគោលដៅ ងាយប្រើប្រាស់ និងក្នុងកម្រិតញឹកញាប់សមស្របជាមួយហានិភ័យទាំងនោះ។ ត្រូវមានការប្រុងប្រយ័ត្នដើម្បីឲ្យប្រាកដថា របាយការណ៍នោះនឹងមិនបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានបន្ថែមទៀតសម្រាប់

ក្រុមអ្នកពាក់ព័ន្ធដែលជាអ្នករងគ្រោះឡើយ។

៣.៤.២.៣ ទម្រង់សមស្របសម្រាប់រាយការណ៍អំពីវឌ្ឍនភាព អាចរាប់បញ្ចូល ការប្រាស្រ័យទាក់ទងជាលក្ខណៈបុគ្គល ការសន្ទនាអនឡាញ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដែលរងគ្រោះ និងរបាយការណ៍ផ្លូវការជាសាធារណៈ។ របាយការណ៍ផ្លូវការ អាចរាប់បញ្ចូល របាយការណ៍ប្រចាំឆ្នាំ របាយការណ៍គណនេយ្យភាព និងនិរន្តរភាពរបស់សហគ្រាស របាយការណ៍អនឡាញ និងរបាយការណ៍ហិរញ្ញវត្ថុចម្រុះ និង របាយការណ៍មិនមែនហិរញ្ញវត្ថុ។

# ជំពូក ៤. ការវិនិយោគបឋម

ការវាយតម្លៃ និងការទប់ស្កាត់

ផ្នែកនៃមានគោលដៅ ជួយសហគ្រាស ធ្វើការវាយតម្លៃហានិភ័យដែលអាចមាន និងផលប៉ះពាល់នៃការវិនិយោគដែលទាក់ទងនឹងបរិស្ថានសង្គម កម្មសិទ្ធិដី បរិស្ថានធម្មជាតិ និងស្ថិរភាពសេដ្ឋកិច្ច មុនធ្វើការវិនិយោគ។ ផ្នែកនេះមានគោលដៅជួយឲ្យសហគ្រាសអាចវិភាគហានិភ័យ និងបង្កើតប្រព័ន្ធផ្តល់ព័ត៌មានជាមុនប្រកបដោយប្រសិទ្ធភាព និងវិធានការតបដើម្បីសម្រេចបានការអភិវឌ្ឍដោយចីរភាព។

## ៤.១ បរិស្ថានសង្គម

### ៤.១.១ អភិបាលកិច្ចប្រទេស

៤.១.១.១ ដើម្បីកំណត់អត្តសញ្ញាណភូមិសាស្ត្រនយោបាយ ប្រព័ន្ធនយោបាយ និងទំនាក់ទំនងភូមិសាស្ត្រនិយោបាយជាលក្ខណៈប្រព័ន្ធ នៃប្រទេស ឬតំបន់នានា ដែលជាកន្លែងត្រូវធ្វើការវិនិយោគ និងវាយតម្លៃឲ្យបានពេញលេញនូវហានិភ័យដែលអាចមាន បណ្តាលពីកត្តាទាំងនេះ ចំពោះការវិនិយោគដែលស្នើឡើង។ ការវិនិយោគនៅក្នុងតំបន់ដែលមានភាពផុយស្រួយខាងនយោបាយ ឬ តំបន់ដែលងាយមានជម្លោះ ត្រូវតែបានទទួលការពិចារណាដោយប្រុងប្រយ័ត្ន។

៤.១.១.២ គួរមានការយល់ដឹងពេញលេញអំពីសមត្ថភាពរបស់ប្រទេសជាម្ចាស់ផ្ទះខាងអភិបាលកិច្ចនយោបាយ និងសង្គម។ ប្រការនេះមិនកំហិតត្រឹមតែ ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែរាប់បញ្ចូលផងដែរនូវ ឯករាជ្យភាពខាងតុលាការ អំពើពុករលួយនៅក្នុងវិស័យសាធារណៈ និងឯកជន ការរំខានខាងនយោបាយមកលើធុរកិច្ច និងកម្រិតនៃការចូលរួមយ៉ាងសកម្មនៃសង្គមស៊ីវិលក្នុងអភិបាលកិច្ច។

៤.១.១.៣ បង្កើនការយល់ដឹងពេញលេញអំពីគោលនយោបាយឧស្សាហកម្ម ការងារ និងពាណិជ្ជកម្ម ការរៀបចំផែនការប្រើប្រាស់ដី និងការរៀបចំផែនការអភិវឌ្ឍន៍ព្រៃឈើ នៅក្នុងប្រទេស និងតំបន់ ដែលជាកន្លែងគ្រោងធ្វើការវិនិយោគ។ គួរធ្វើការវាយតម្លៃផលប៉ះពាល់ដែលអាចមានបណ្តាលពីគោលនយោបាយទាំងនោះមកលើសំណើគម្រោងនោះ។

៤.១.១.៤ គួរពិចារណាលក្ខខណ្ឌតម្រូវខាងការងារនៃគម្រោង និងវត្តមានការងារក្នុងមូលដ្ឋាន។ ប្រសិនបើលក្ខខណ្ឌការងារក្នុងមូលដ្ឋានតម្រូវ គួរតែមានការពិចារណាដោយប្រុងប្រយ័ត្នចំពោះលក្ខខណ្ឌនេះនៅក្នុងការវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

៤.១.១.៥ គួរធ្វើការវាយតម្លៃពេញលេញនូវផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានមកលើស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គម និងបរិស្ថាននៃប្រទេសជាម្ចាស់ផ្ទះ ឬសហគមន៍មូលដ្ឋាន បណ្តាលពីការ

សម្រេចធ្វើការវិនិយោគ និងរៀបចំវិធានការឆ្លើយតប ដើម្បីទប់ស្កាត់ និងគ្រប់គ្រងផលប៉ះពាល់ដែលអាចកើតមានទាំងនោះ។

### ៤.១.២ អង្គការសង្គមស៊ីវិល

៤.១.២.១ គួរកំណត់អត្តសញ្ញាណអង្គការសង្គមស៊ីវិល ដែលមានឥទ្ធិពលគ្រប់គ្រាន់មកលើសហគមន៍ និងមតិសាធារណៈ និងដែលមានទស្សនៈស៊ីជម្រៅអំពីអ្នកនយោបាយនៅមូលដ្ឋាន សេដ្ឋកិច្ច សង្គម បរិស្ថាន។ល។ គួរស្វែងយល់ឲ្យបានពេញលេញនូវគំនិតចំបងៗរបស់ពួកគេ ការអំពាវនាវ ឥទ្ធិពល និងវិសាលភាពនៃសកម្មភាពរបស់អង្គការទាំងនោះ។

៤.១.២.២ គិតគូរឲ្យបានពេញលេញនូវឥទ្ធិពលផ្ទាល់ និងប្រយោលនៃអង្គការសង្គមស៊ីវិលមកលើសំណើគម្រោង។ គួរបង្កើតយន្តការប្រាស្រ័យទាក់ទង និងកសាងភាពជាដៃគូសហការនៅលំដាប់ថ្នាក់ខុសៗគ្នាតាមការចាំបាច់។

### ៤.១.៣ ទំនាក់ទំនងសហគមន៍

៤.១.៣.១ គួរកំណត់អត្តសញ្ញាណសហគមន៍ និងធ្វើឲ្យពួកគេចូលរួមនៅក្នុងការកំណត់វិសាលភាពគម្រោង ជូនដំណឹងដល់ពួកគេអំពីគម្រោងវិនិយោគ និងផលប៉ះពាល់នៃគម្រោងទាំងនោះ ដែលរួមទាំងលទ្ធផលនៃការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមដែលបានអនុវត្ត។ ត្រូវគោរពសិទ្ធិរបស់សហគមន៍ក្នុងការឯកភាពមតិដោយគ្មានការបង្ខិតបង្ខំ ជាមុន និងជាមួយព័ត៌មានពេញលេញ។

៤.១.៣.២ គួរបង្កើនការយល់ដឹងឲ្យបានស៊ីជម្រៅអំពីវប្បធម៌ គុណតម្លៃ សាសនា និងប្រពៃណីរបស់សហគមន៍មូលដ្ឋាន (ដែលរួមទាំងរបស់ជនជាតិដើមភាគតិច) នៅក្នុងតំបន់សំណើគម្រោង ដើម្បីការពារភាពចម្រុះនៃវប្បធម៌ និងលើកស្ទួយបរិយាប័ន្ន។ គួរកំណត់អត្តសញ្ញាណផលប៉ះពាល់ដែលអាចកើតមានដោយសារសំណើគម្រោង ឬប្រតិបត្តិការគម្រោង។ គួររៀបចំផែនការកាត់បន្ថយជាមុន ដើម្បីជៀសវាង ឬកាត់បន្ថយឲ្យនៅកម្រិតអប្បបរមានូវផលប៉ះពាល់អវិជ្ជមាន។

៤.១.៣.៣ គួរគិតគូរពីផលប៉ះពាល់មកលើបរចិញ្ចឹមជីវិតរបស់កសិករតូចតាច ដោយសារតែគម្រោង និងចាត់ចែងសម្រាប់ការចូលរួមរបស់ពួកគាត់នៅក្នុងដំណើរការនៃការផលិតកៅស៊ូធម្មជាតិ ការកែច្នៃ ឬផ្នែកនានាដទៃទៀតនៃគំរូធុរកិច្ចនេះ។ គួរពិចារណាលក្ខខណ្ឌតម្រូវអំពីការអភិវឌ្ឍសមត្ថភាព ដែលចាំបាច់ត្រូវមាន ដើម្បីសម្រួលការចូលរួមពីសំណាក់កសិករតូចតាច។

៤.១.៣.៤ ប្រការសំខាន់គឺគួរជៀសវាងការរំលោភសិទ្ធមនុស្ស។ គួរធ្វើការវាយតម្លៃផលប៉ះពាល់ដែលអាចមានមកលើសិទ្ធិមនុស្សជាមូលដ្ឋាន ដែលអាចបង្កឡើងដោយសារសកម្មភាព និងទំនាក់ទំនងធុរកិច្ច នៃក្រុមហ៊ុនពាក់ព័ន្ធ ឬអ្នកផ្គត់ផ្គង់ ដែលរួមទាំង សន្តិសុខស្បៀង និងការជម្រុញជាបន្តបន្ទាប់នូវសិទ្ធិក្នុងការ

ទទួលបានស្បៀងអាហារគ្រប់គ្រាន់ សិទ្ធិមានលំនៅស្ថានគ្រប់គ្រាន់ សិទ្ធិចំពោះសេរីភាពក្នុងការចូលរួមជាសមាគម និងសិទ្ធិចំពោះការសំដែងមតិ និងការជួបប្រជុំ។

៤.១.៣.៥ ស្របតាមបទប្បញ្ញត្តិនៅថ្នាក់ជាតិរបស់ប្រទេស និងទម្លាប់អនុវត្តល្អៗជាអន្តរជាតិ គួរធ្វើការវាយតម្លៃផលប៉ះពាល់ជាក់លាក់មកលើកន្លែងនានា ដែលត្រូវធ្វើការវិនិយោគ ជាពិសេសកន្លែងមានជនជាតិដើមរស់នៅ ដោយគិតគូរឲ្យបានពេញលេញអំពិសិទ្ធិរបស់ពួកគេចំពោះដីធ្លី ដែនដីជាកន្លែងរស់នៅ និងធនធានធម្មជាតិដែលជាបង្អែករបស់ពួកគេ ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមាន។ ត្រូវស្វែងរកការឯកភាពដោយគ្មានការបង្ខំ ជាមុន និងជាមួយព័ត៌មានគ្រប់គ្រាន់ មុនប្រកាន់យក និងការអនុវត្តវិធានការនានាដែលអាចប៉ះពាល់ដល់ពួកគេ។

៤.១.៣.៦ ត្រូវកំណត់អត្តសញ្ញាណកន្លែងដែលមានតម្លៃពិសេសខាងវប្បធម៌ និងសហគមន៍ ដូចជាទីលានកប់សព ភ្នំពិសិដ្ឋ ដែនដីពិសិដ្ឋ និងដូចសម្រាប់គោលបំណងខាងសាសនាផងដែរ និងកន្លែងនានាដែលជាទីសក្ការៈដូនតា នឹងមិនរៀបចំផែនការអភិវឌ្ឍន៍ដីធ្លីនៅទីនោះឡើយ ដើម្បីបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើទីកន្លែង និងទីតាំងបែបនោះ។

## ៤.២ កម្មសិទ្ធិដី

### ៤.២.១ ការបញ្ជាក់អំពីសិទ្ធិចំពោះដីធ្លី

៤.២.១.១ មុននឹងធ្វើការសម្រេចអំពីគម្រោងណាមួយ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដី ត្រូវព្យាយាមស្វែងយល់ឲ្យបានពេញលេញអំពីច្បាប់ និងបទប្បញ្ញត្តិនានាដែលទាក់ទងនឹងដីធ្លី និងអំពីការរៀបចំផែនការនិងព័ត៌មានអំពីការប្រើប្រាស់ នៅក្នុងកន្លែងដែលស្នើសម្រាប់ការវិនិយោគ។ ត្រូវកំណត់អត្តសញ្ញាណ និងវាយតម្លៃកម្មសិទ្ធិលើចំណែកដីដែលត្រូវការសម្រាប់គម្រោង។

៤.២.១.២ ត្រូវធ្វើការវាយតម្លៃពេញលេញអំពីសិទ្ធិកាន់កាប់តាមប្រពៃណី និងសិទ្ធិប្រើប្រាស់ដែលទាក់ទងនឹងដីធ្លី ទឹក ព្រៃឈើ និងធនធានធម្មជាតិដទៃទៀត។ ត្រូវគោរពសិទ្ធិកាន់កាប់តាមប្រពៃណីរបស់សហគមន៍មូលដ្ឋាន។ ត្រូវធានាថាសិទ្ធិស្របច្បាប់របស់ពួកគាត់មិនត្រូវបានរំលោភឡើយ។

### ៤.២.២ ការទទួលបានសិទ្ធិចំពោះដីធ្លី

៤.២.២.១ ត្រូវស្វែងយល់ឲ្យបានពេញលេញអំពីច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីច្បាប់ ដែលពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មចំពោះសិទ្ធិដីធ្លីសម្រាប់កន្លែងដែលត្រូវវិនិយោគ នៅក្នុងដែនសមត្ថកិច្ចនៃប្រទេសនោះ។ ត្រូវវាយតម្លៃការទទួលខុសត្រូវ និងកាតព្វកិច្ចនៅក្រោមច្បាប់ និងបទប្បញ្ញត្តិទាំងនោះ និងត្រូវស្វែងយល់ពីថ្លៃចំណាយដើម្បីគោរពតាមច្បាប់ និងបទប្បញ្ញត្តិទាំងនោះ។ ត្រូវធ្វើការវាយតម្លៃអំពីរបៀបគោរពតាមនីតិវិធីលទ្ធកម្មសម្រាប់លិខិតអនុញ្ញាតធុរកិច្ចលើដីធ្លី និងលក្ខខណ្ឌដែលពាក់ព័ន្ធនៅក្នុងច្បាប់និងបទប្បញ្ញត្តិពាក់

ព័ន្ធទាំងនោះ។

៤.២.២.២ ត្រូវស្វែងយល់ឲ្យបានពេញលេញអំពីការរៀបចំផែនការប្រើប្រាស់ដី នៅកន្លែងដែលត្រូវវិនិយោគ និងធ្វើការវិភាគ និងប៉ាន់ប្រមាណអំពីគុណផលនៃការប្រើប្រាស់ដីសម្រាប់ការសាងសង់ ជាមួយលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដី។

៤.២.២.៣ គួរជៀសវាងការជន្លៀសដោយបង្ខំ ទោះបីអាចធ្វើបានស្របតាមគោលការណ៍របស់អ.ស.ប "កិច្ចការពារ គោរព និងជួសជុល"ស្តីពីសិទ្ធិមនុស្សក៏ដោយ។ ក្នុងករណីដែលចាំបាច់ត្រូវជន្លៀស ក្រុមហ៊ុនគួរចូលរួមធ្វើការជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីឲ្យមានការព្រមព្រៀងលើសំណង ការតាំងលំនៅស្ថានជាថ្មី និង/ឬ ការប្តូរទីតាំងដោយសមស្របដោយគ្នាលំអៀង និងសមហេតុផល។ ការប្តូរទីតាំងពុំគួរនាំឲ្យបុគ្គលនានាក្លាយជាគ្មានផ្ទះសំបែង ឬងាយរងគ្រោះចំពោះមុខអំពើរំលោភសិទ្ធិមនុស្សឡើយ។

៤.២.២.៤ មិនត្រូវឈានទៅធ្វើការវិនិយោឡើយ ប្រសិនបើលទ្ធផលនៃការវាយតម្លៃបង្ហាញពីផលប៉ះពាល់អវិជ្ជមានដែលអាចមានកម្រិតខ្ពស់ គម្រោងដែលគ្រោងនោះពុំអាចទទួលបាន FPIC ពីជនជាតិដើមភាគតិច ឬពុំមានការឈានដល់ការមូលមតិលើការតាំងទីលំនៅឡើងវិញ ឬកម្មវិធីទូទាត់សំណង។

### ៤.២.៣ ការផ្ទេរដីធ្លី និងការស្តារឡើងវិញ

៤.២.៣.១ នៅក្នុងពេលចាប់ផ្តើមដំបូងនៃគម្រោងដែលពាក់ព័ន្ធជាមួយការជួលដី ឬសម្បទានសម្រាប់ការប្រើប្រាស់ដីដែលមានកាលកំណត់ ចូរពិចារណាអំពីវិធីផ្ទេរដីទៅឲ្យប្រទេស ឬសហគមន៍ដើមវិញ នៅពេលចប់គម្រោង។ លក្ខខណ្ឌនៃការផ្ទេរដីធ្លី (ដែលរួមទាំង ក្រម និងលក្ខខណ្ឌនៃការផ្ទេរដីត្រឡប់ទៅម្ចាស់ដើមវិញ) ត្រូវតែបានពិភាក្សាជាផ្នែកមួយនៃនីតិវិធី FPIC។

## ៤.៣ បរិស្ថានធម្មជាតិ

### ៤.៣.១ ចំការកៅស៊ូ

៤.៣.១.១ ចូរកំណត់អត្តសញ្ញាណសណ្ឋានដី ទម្រង់ដី ទឹកក្រោមដី ទឹកលើផ្ទៃដី ស្រទាប់ក្រោមដី និងរបាយសារជាតុរ៉ែ នៃកន្លែងដែលត្រូវដាំ ក៏ដូចជាតំបន់ដីសើម (វាលភក់ បឹង អាងទឹក កន្លែងលិចទឹក) និងទន្លេនានា នៅក្នុងកន្លែងស្នើឡើង និងវាយតម្លៃភាពងាយរងគ្រោះខាងបរិស្ថាននៃកន្លែងទាំងនោះ ដោយសារតែផលប៉ះពាល់បរិស្ថានដែលអាចកើតមាន ដែលអាចបង្កឡើងដោយសំណើគម្រោងនោះ។

៣.៤.១.២ ចូរកំណត់អត្តសញ្ញាណលក្ខខណ្ឌឧតុនិយម (ដូចជា កំពស់ទឹកភ្លៀង សីតុណ្ហភាព សំណើមប្រពលភាពនៃពន្លឺថ្ងៃ ល្បឿនខ្យល់។ល។) សារជាតុរ៉ែនៃដី ជំងឺដែលអាចមាន និងកត្តាចង្រៃនៃកន្លែងដាំ និងវាយតម្លៃ ភាពសមស្របខាងអេកូឡូស៊ីនៃការដាំកៅស៊ូ។

៤.៣.១.៣ ចូរកំណត់អត្តសញ្ញាណប្រភេទដី និងរបាយប្រភេទដី ដែលរួមទាំងលក្ខណៈរូប និងគីមីនៃដី ដីជាតិដី លក្ខណៈសមស្របនៃដី។ ចូរកំណត់អត្រាផ្ទៃដីដែលសមស្រប និងទំហំដែលមិនសមស្របសម្រាប់ការដាំ ចូរជ្រើសរើសយកវិធីដាំសមស្រប ឬគំរូកសិកម្មចម្រុះ។

៤.៣.១.៤ ចូរអភិរក្សជីវចម្រុះ និងបំពេញគោលការណ៍នៃអត្រាបាត់បង់ព្រៃឈើស្មើសូន្យ។ ចូរកំណត់អត្តសញ្ញាណថាតើ មានកន្លែងដែលមានតម្លៃខ្ពស់ខាងការអភិរក្ស (HCV) កន្លែងមានស្តុកកាបូនខ្ពស់ (HCS) នៅក្នុងកន្លែងស្នើសម្រាប់ការវិនិយោគ។ ចូរកំណត់អត្តសញ្ញាណប្រភេទឈើ រុក្ខជាតិវល្លិ និងរុក្ខជាតិស្មៅ ដែលមានតម្លៃសម្រាប់ការអភិរក្ស សត្វព្រៃ និងត្រី ទាក់ទងនឹងសារៈសំខាន់ខាងជីវចម្រុះ។ ចូរកំណត់អត្តសញ្ញាណដង់ស៊ីព្រៃឈើ រុក្ខជាតិព្រៃ រុក្ខជាតិដែលប្រើប្រាស់ដោយជនជាតិដើមភាគតិច ឬសហគមន៍មូលដ្ឋាន និងធនធានសេនេទិកកសិកម្ម រុក្ខជាតិកៅស៊ូ ក្នុងគោលបំណងការពារជីវចម្រុះ និងមុខងារសេវាកម្មអេកូឡូស៊ី ឲ្យបានច្រើនតាមតែអាចធ្វើបាន។

៤.៣.១.៥ ចូរសិក្សាច្បាប់ និងបទប្បញ្ញត្តិនៅមូលដ្ឋាន ដើម្បីកំណត់អត្តសញ្ញាណកម្មសិទ្ធិដីតាមប្រពៃណី។ ចូរកំណត់អត្តសញ្ញាណ និងការពារទម្លាប់តាមប្រពៃណីរបស់ជនជាតិដើមភាគតិច និងឥទ្ធិពលរបស់ពួកគេមកលើធនធានជីវសាស្ត្រ ដីធ្លី និងធនធានបរិស្ថានផ្សេងទៀត។ ចូរគោរពកម្មសិទ្ធិតាមប្រពៃណី។ ចូរការពារភាពចម្រុះនៃវប្បធម៌ និងជៀសវាងជម្លោះ ដោយសារតែភាពខុសគ្នានៃវប្បធម៌ និងប្រពៃណី។

៤.៣.១.៦ ចូរកាត់បន្ថយរាល់ផលប៉ះពាល់អវិជ្ជមានខាងបរិស្ថាននៃចំការកៅស៊ូ។ ចំការកៅស៊ូត្រូវបានហាមឃាត់នៅលើដីដែលមានចំណោតខ្លាំង កន្លែង HCV កន្លែង HCS និងកន្លែងអភិរក្សតាមដងទន្លេ។ ប្រព័ន្ធដំណាំចម្រុះគួរតែបានយកមកអនុវត្ត ដែលរួមទាំង ការដាំដំណាំឆ្លាស់ និងដំណាំតគ្នា ដើម្បីគ្រប់គ្រងរុក្ខជាតិស្រទាប់ក្រោម ការពារគម្របដី កាត់បន្ថយការហូរច្រោះ កែលំអសុខភាពដី ពង្រីកជីវចម្រុះ និងថែរក្សាមុខងារអេកូឡូស៊ីនៃចំការកៅស៊ូ។

៤.៣.១.៧ នៅពេលដាំដើមកៅស៊ូលើដីដែលមានលក្ខណៈអេកូឡូស៊ីផុយស្រួយ ដីព្រៃរេចរឹល និងដីចោលទំនេរ ប្រការចាំបាច់គឺត្រូវកត់ត្រា និងវិភាគសមាសភាពសហគមន៍រុក្ខជាតិ សកម្មភាពប្រើប្រាស់ដី និងកត្តាធម្មជាតិ និង/ឬមនុស្ស ដែលនាំឲ្យរេចរឹល ឬវិនាស និងវាយតម្លៃកត្តាទាំងនេះមកលើលទ្ធភាពនៃការដាំ។ មិនគួរដាំដើមកៅស៊ូនៅលើដីចំការកៅស៊ូចាស់ដែលមានបរិស្ថានអេកូឡូស៊ីផុយស្រួយ កន្លែងបាត់បង់ធនធានទឹក និងកន្លែងដែលមានការហូរច្រោះដី និងឱនភាពដីធ្ងន់ធ្ងរឡើយ។ នៅកន្លែងបែបនោះ គួរតែមានការស្តារុក្ខជាតិឡើងវិញ ដើម្បីកាត់បន្ថយផលប៉ះពាល់មកលើបរិស្ថានបណ្តាលពីការដាំកៅស៊ូ។

៤.៣.១.៨ ផលប៉ះពាល់មកលើបរិស្ថាន និងភាពបន្សាំបាន ត្រូវតែបានវាយតម្លៃ មុនដាំឡើងវិញនៅក្នុងចំការកៅស៊ូចាស់ ដើម្បីកំណត់អត្រាលូតលាស់ឡើងវិញ និងគិតគូរពីលទ្ធភាពនៃការស្តារព្រៃឈើឡើងវិញ។

### ៤.៣.២ រោងចក្រកែច្នៃកៅស៊ូឆៅ

៤.៣.២.១ ចូរកំណត់អត្តសញ្ញាណទីតាំងសំណង់ដែលមានអនុលោមភាពជាមួយលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការនៅមូលដ្ឋាន។ ប្រការចាំបាច់គឺត្រូវកំណត់អត្តសញ្ញាណវាលរាប សណ្ឋានដី ឧតុនិយម ជលសាស្ត្រ ភូគព្ភសាស្ត្រ និងលក្ខខណ្ឌធម្មជាតិដទៃទៀត ក៏ដូចជា ការដឹកជញ្ជូន ថាមពល ពលកម្ម និងលក្ខខណ្ឌសង្គម និងសេដ្ឋកិច្ចដទៃទៀតនៃទីកន្លែងសាងសង់រោងចក្រកែច្នៃកៅស៊ូឆៅ និងវាយតម្លៃថាតើវាឆ្លើយតបនឹងលក្ខខណ្ឌតម្រូវសម្រាប់ការសាងសង់ឬទេ។

៤.៣.២.២ ចូរកំណត់អត្តសញ្ញាណថាតើកន្លែងសាងសង់ស្ថិតនៅចម្ងាយដែលមានសុវត្ថិភាពពីទីកន្លែងតាំងទីលំនៅរបស់មនុស្ស ទីតាំងវប្បធម៌ និងសាសនា កន្លែងវេជ្ជសាស្ត្រ និងអប់រំ កន្លែងអភិរក្សទឹក បូជនីយស្ថាន ទីកន្លែងមានទេសភាពត្រកាល និងដែនបម្រុងធម្មជាតិ ស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធឬទេ។ ទិសខ្យល់បក់គួរតែបានពិចារណាផងដែរ ដើម្បីបញ្ចៀសផលអវិជ្ជមាននៃក្លិនមិនសមស្រប។

៤.៣.២.៣ ចូរកំណត់អត្តសញ្ញាណវិធី និងលទ្ធភាពនៃកៅស៊ូធម្មជាតិនៅក្នុងកន្លែងសាងសង់ និងកំណត់ប្រភេទពូជ និងលក្ខខណ្ឌបច្ចេកទេសនៃកៅស៊ូដែលបានស្នើសម្រាប់ដាំ។ ប្រការចាំបាច់ផងដែរគឺត្រូវបញ្ជាក់ថាតើ លក្ខណៈបច្ចេកទេស និងសមត្ថភាពស្របគ្នាជាមួយលក្ខខណ្ឌតម្រូវនៃគោលនយោបាយឧស្សាហកម្មក្នុងមូលដ្ឋាន ផែនការអភិវឌ្ឍន៍ឧស្សាហកម្ម គោលនយោបាយបច្ចេកទេស និងលក្ខណៈបច្ចេកទេសនៃផលិតផលឬទេ។

៤.៣.២.៤ ផលប៉ះពាល់នៃរោងចក្រមកលើបរិស្ថានគួរតែបានកំណត់អត្តសញ្ញាណ ជាពិសេសមកលើការផ្គត់ផ្គង់ទឹក និងប្រព័ន្ធលូដោះទឹក និងគួរធានាអនុលោមភាពជាមួយបទប្បញ្ញត្តិបរិស្ថានក្នុងមូលដ្ឋាន។ ការរៀបចំផែនការ និងរចនាបថ គួរតែបញ្ចូលសម្បទាសម្រាប់ប្រព្រឹត្តកម្មសំអាត"សំណល់បី"(ពោលគឺសំណល់ឧស្ម័ន សំណល់រាវ និងសំណល់រឹង) ដែលផលិតដោយរៀងចក្រ និងដើម្បីទប់ស្កាត់ភាពក្រខ្វក់នៃប្រភពទឹក។

៤.៣.២.៥ ចូរកំណត់អត្តសញ្ញាណបញ្ហាបរិស្ថាននៃរោងចក្រដែលមានស្រាប់ និងស្វែងរកដំណោះស្រាយចំពោះបញ្ហាទាំងនោះសម្រាប់ការអនុវត្ត។ ត្រូវអនុវត្តដំណោះស្រាយចំពោះបញ្ហាបែបនោះ។ លើសពីនេះត្រូវកំណត់អត្តសញ្ញាណលក្ខខណ្ឌសមស្រប និងវិធានការកែលំអ ដែលនឹងកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ការសាងសង់។

## ៤.៤ ស្ថិរភាពសេដ្ឋកិច្ច

### ៤.៤.១ បរិស្ថានសេដ្ឋកិច្ច

៤.៤.១.១ គួរមានការកំណត់ហានិភ័យសេដ្ឋកិច្ច។ ប្រការសំខាន់គឺត្រូវស្វែងយល់ថាការវិនិយោគអាចរង

ការប៉ះពាល់ ដោយបរិស្ថានធម្មជាតិ ហិរញ្ញវត្ថុអន្តរជាតិ ភាពប្រែប្រួលខាងនយោបាយ ចលាចលក្នុងសង្គម វិបត្តិសេដ្ឋកិច្ច បច្ចេកវិទ្យាផលិត និងហានិភ័យដទៃទៀត។ ការវាយតម្លៃហានិភ័យ គួរតែបានធ្វើឡើង មុននឹងធ្វើការវិនិយោគ។ នៅក្នុងការវាយតម្លៃហានិភ័យខាងសេដ្ឋកិច្ច គួរតែមានការវាយតម្លៃហានិភ័យនៃការប្រែប្រួលអត្រាប្តូរប្រាក់ សមត្ថភាពទប់ទល់នឹងហានិភ័យនៃការវិនិយោគដើមទុនសម្រាប់រយៈពេលវែង និងកម្រិតនៃការវិនិយោគដែលមិនអាចគ្រប់គ្រងបាន។ ការវិភាគតាមបែបវិជ្ជាជីវៈលើហិរញ្ញវត្ថុគួរតែបានអនុវត្ត ហើយផែនការធុរកិច្ច គួរតែបានរៀបចំ។

៤.៤.១.២ គួរកំណត់អត្តសញ្ញាណហានិភ័យប្រតិបត្តិការ។ មុនធ្វើការវិនិយោគ គួរតែមានការវាយតម្លៃកិច្ចសន្យាហិរញ្ញវត្ថុទៅអនាគត ចំការកៅស៊ូ និងឧស្សាហកម្មកែច្នៃ និងឧស្សាហកម្មប្រើប្រាស់ផលិតផលនៅចុងខ្សែ។ និន្នាការអភិវឌ្ឍន៍សេដ្ឋកិច្ច និងផលប៉ះពាល់នៃការប្រែប្រួលសេដ្ឋកិច្ចនៅក្នុងអំឡុងពេលផលិត ក៏គួរតែបានវាយតម្លៃផងដែរ។ គួរធ្វើការវិភាគបឋមនៃប្រតិបត្តិការ។

៤.៤.១.៣ សេដ្ឋកិច្ចនយោបាយ និងហានិភ័យនយោបាយ គួរតែបានកំណត់អត្តសញ្ញាណ។ ប្រការចាំបាច់គឺត្រូវយល់ថា ការវិនិយោគអាចស្ថិតក្រោមឥទ្ធិពលនៃការរៀបចំផែនការឧស្សាហកម្ម ការកំហិតនៅជីផ្លីគោលនយោបាយនាំចូល និងនាំចេញ ក៏ដូចជា សេដ្ឋកិច្ចនយោបាយផងដែរ។ ការវិភាគនយោបាយ និងសេដ្ឋកិច្ចនយោបាយ គួរតែបានអនុវត្ត មុនមានការវិនិយោគ ហើយគួរតែបានធ្វើការវិភាគបឋមលើគោលនយោបាយ។

### ៤.៤.២ បរិស្ថានទីផ្សារ

៤.៤.២.១ គួរមានការកំណត់ហានិភ័យទីផ្សារ។ ប្រការសំខាន់គួរស្វែងយល់ថា ទីផ្សារកៅស៊ូធម្មជាតិអាចរងការប៉ះពាល់ដោយសារសមត្ថភាពផ្គត់ផ្គង់លើពិភពលោកនិងក្នុងតំបន់ ផលិតករ អ្នកបរិភោគ អ្នកប្រើប្រាស់ គូប្រជែង និងកត្តាដទៃទៀតឬទេ។ មុនធ្វើការវិនិយោគ គួរធ្វើការវិភាគដោយផ្តោតលើស្ថានភាពនៃការផ្គត់ផ្គង់ និងតម្រូវការនៃកន្លែងស្នើសម្រាប់ការវិនិយោគ និងនៃតំបន់ប្រើប្រាស់ ក៏ដូចជា ហានិភ័យនៃទីផ្សារកៅស៊ូធម្មជាតិផងដែរ។ គួរមានការវាយតម្លៃគូប្រជែងក្នុងទីផ្សារ អ្នកប្រើប្រាស់ និងសមត្ថភាពសរុបនៃកៅស៊ូធម្មជាតិ និងការវិភាគហានិភ័យនៃទីផ្សារផងដែរ។

៤.៤.២.២ គួរកំណត់អត្តសញ្ញាណហានិភ័យនៃប្រតិបត្តិការ។ កៅស៊ូធម្មជាតិ គឺជាផលិតផលមួយសម្រាប់អនាគត ហើយផលចំណេញអាចរងការប៉ះពាល់ ដោយសារប្រតិបត្តិការណាមួយ ការដោះដូរទំនិញទៅអនាគត និងសមាមាត្រនៃកិច្ចសន្យាហិរញ្ញវត្ថុ។ មុនធ្វើការវិនិយោគ គួរធ្វើការវិភាគគំរូពាណិជ្ជកម្មកៅស៊ូធម្មជាតិ ផ្លូវដឹកជញ្ជូន និងថ្លៃចំណាយ ក៏ដូចជា ការវិភាគហានិភ័យនៃប្រតិបត្តិការផងដែរ។

៤.៤.២.៣ គួរកំណត់ហានិភ័យខាងភស្តុភា។ កៅស៊ូធម្មជាតិគឺជាផលិតផលមួយសម្រាប់លក់ដុំ ដូច្នេះ ការ

ដឹកជញ្ជូនថ្នាក់តំបន់ និងបរិស្ថានខាងកស្ដុភា គឺជាកត្តាសំខាន់មួយដែលប៉ះពាល់មកលើផលចំណេញ។ មុនធ្វើការវិនិយោគ គួរធ្វើការវិភាគ ដោយផ្ដោតលើក្រុមហ៊ុនដែលផ្គត់ផ្គង់ផលិតផល និងហេដ្ឋានរចនាសម្ព័ន្ធ ដើម្បីពិនិត្យវត្តមាន និងប្រភេទនៃយានយន្តសម្រាប់កាដឹកជញ្ជូន សម្បទាដឹកជញ្ជូន បរិក្ខារ ថ្លៃ ការផ្គត់ផ្គង់ និងតម្រូវការ។

### ៤.៤.៣ បរិស្ថានបច្ចេកទេស

៤.៤.៣.១ គួរកំណត់អត្តសញ្ញាណហានិភ័យអំពីវត្តមានធនធានមនុស្ស និងអ្នកឯកទេសជំនាញ។ បច្ចេកវិទ្យា គឺជាតម្រូវការខ្ពស់នៅទូទាំងការដាំកៅស៊ូ ការកែច្នៃ ការធ្វើពាណិជ្ជកម្ម និងការដឹកជញ្ជូន ដូច្នេះប្រការសំខាន់គឺត្រូវសិក្សាលទ្ធភាពទទួលបានបច្ចេកវិទ្យា និងអ្នកជំនាញសមស្រប ជាពិសេសវត្តមានអ្នកឯកទេសលើផ្នែកដំណាំកៅស៊ូ និងបច្ចេកវិទ្យាកែច្នៃ ហិរញ្ញវត្ថុ និងធុរកិច្ច និងវត្តមានកម្លាំងពលកម្ម។

៤.៤.៣.២ គួរកំណត់អត្តសញ្ញាណហានិភ័យបច្ចេកទេសដែលទាក់ទងនឹងការដាំកៅស៊ូ។ ប្រភេទដើមកៅស៊ូដែលត្រូវដាំ អាស្រ័យទៅតាមបរិស្ថាន អាកាសធាតុ ដី និងកត្តាដទៃទៀត។ ផលិតផលកៅស៊ូ ដែលត្រូវផលិត អាស្រ័យជាសំខាន់លើទីផ្សារប្រើប្រាស់នៅចុងខ្សែ។ វត្តមាន និងភាពសមស្របនៃប្រភេទដើមកៅស៊ូ ដែលត្រូវដាំ និងកែច្នៃដើម្បីទទួលបានកៅស៊ូក្នុងកម្រិតគុណភាពខុសៗគ្នា គួរតែបានពិចារណាផងដែរ និងគួរធ្វើការចាត់ចែងអនុលោមតាមការនិយម និងតម្រូវការរបស់អតិថិជន។

៤.៤.៣.៣ គួរកំណត់អត្តសញ្ញាណហានិភ័យដែលពាល់ព័ន្ធ និងបរិក្ខារកែច្នៃ។ ប្រការចាំបាច់គឺត្រូវស្វែងយល់អំពីថាតើស្វ័យប្រវត្តិកម្មនៃបរិក្ខារកែច្នៃនឹងមានការប៉ះពាល់បែបណាមកលើទិដ្ឋភាពនានានៃគម្រោងដែលរួមទាំង ការវិនិយោគ ការផលិត ផលចំណេញ និងតម្រូវការពលកម្ម។ គួរសម្រេចឲ្យបាននូវទំនាក់ទំនងមួយដែលមានតុល្យភាពរវាងកត្តានានាខាងលើ បច្ចេកវិទ្យា និងបរិក្ខារដែលមានប្រសិទ្ធភាពខាងការចំណាយ ដែលមានអនុលោមភាពជាមួយលក្ខខណ្ឌតម្រូវរបស់ប្រទេស និងសមស្របសម្រាប់បរិស្ថានក្នុងមូលដ្ឋាន និងបរិបទសង្គម ដែលគួរតែបានដាក់ឲ្យអនុវត្ត ស្របតាមការវិភាគវត្តមាន និងភាពសមស្រប។

# ជំពូក ៥. ការគ្រប់គ្រងនិន្នាការ និងការត្រួតពិនិត្យហានិភ័យនៅក្នុងប្រតិបត្តិការជំនួញ

ផ្នែកនេះកំណត់អត្តសញ្ញាណហានិភ័យចំបងៗខាងសង្គម បរិស្ថាន និងសេដ្ឋកិច្ច និងបញ្ហានៃការទទួលខុសត្រូវ ក្នុងអំឡុងពេលនៃប្រតិបត្តិការចំការកៅស៊ូ និងការកែច្នៃ ព្រមទាំង លក្ខខណ្ឌតម្រូវដាក់លាក់ និងយោបល់អំពីការទប់ស្កាត់ ឬវិធានការគ្រប់គ្រង សម្រាប់ហានិភ័យនានាខាងលើ និងបង្ហាញពីបញ្ហានៃការទទួលខុសត្រូវ។ ផ្នែកនេះមានគោលដៅជួយសហគ្រាសនានាក្នុងការអនុវត្តធុរកិច្ចប្រកបដោយការទទួលខុសត្រូវ ពង្រឹងការប្រាស្រ័យទាក់ទង និងកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធនានា កាត់បន្ថយផលប៉ះពាល់អវិជ្ជមានខាងសង្គម និងបរិស្ថាន ដែលពាក់ព័ន្ធជាមួយសកម្មភាពប្រតិបត្តិការ បន្តកែលម្អគុណផលនៃការទទួលខុសត្រូវនិងសមត្ថភាពខាងអភិបាលកិច្ច ដើម្បីការអភិវឌ្ឍឈ្នះ-ឈ្នះ។

## ៥.១ ការទទួលខុសត្រូវសង្គម

### ៥.១.១ សិទ្ធិសហគមន៍ និងជនជាតិដើមភាគតិច

៥.១.១.១ សិទ្ធិរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចក្នុងការដាំដំណាំ ការផ្ទេរសិទ្ធិ និងប្រើប្រាស់ដី គួរតែបានគោរព ដើម្បីជានាគ្មានការរំលោភលើច្បាប់ដែលមានស្រាប់ ឬដីប្រពៃណី កម្មសិទ្ធិលើទឹក និងព្រៃឈើ។ គួរចាត់វិធានការ ដើម្បីទប់ស្កាត់ឬកាត់បន្ថយផលប៉ះពាល់ដ៏មហន្តរាយ បណ្តាលពីការអនុវត្តនៅក្នុងធុរកិច្ចមកលើសហគមន៍មូលដ្ឋាន និងដើម្បីលើកកំពស់ផលប៉ះពាល់វិជ្ជមាន។

៥.១.១.២ គួរពង្រឹងភាពអង់អាចរបស់សហគមន៍មូលដ្ឋាន ដើម្បីឲ្យពួកគេចូលរួមនៅក្នុងគម្រោងនេះ ជាដៃគូក្នុងធុរកិច្ចនៅក្នុងករណីដែលអាចធ្វើបាន តាមរយៈ ដូចជា ប្រព័ន្ធដាំសម្រាប់លក់ ការផ្តល់សេវានានានៅក្នុងចំការកៅស៊ូ និងការងារនៅក្នុងរោងចក្រកែច្នៃ។

៥.១.១.៣ សហគ្រាសនានាត្រូវគិតគូរឲ្យបានពេញលេញអំពីផលប៉ះពាល់បរិស្ថាន សុខភាពនិងសុវត្ថិភាពនៃប្រតិបត្តិការនេះ មកលើសហគមន៍មូលដ្ឋាន និងចាត់វិធានការសមស្របដើម្បីទបស្កាត់ ឬបញ្ចៀសផលប៉ះពាល់អចិជ្ជមាន។

៥.១.១.១៤ គួរស្វែងយល់ថាសហគមន៍គឺជារចនាសម្ព័ន្ធមួយស្រទាប់នៅក្នុងរចនាសម្ព័ន្ធជាច្រើនស្រទាប់នៃសង្គម និងជាក្រុមដែលមានថាមពលខ្លាំងក្លា និងឌីណាមិក និងមានទស្សនៈខុសៗគ្នា។ ចំពោះបញ្ហានានាដែលទាក់ទងនឹងសិទ្ធិ និងផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន គួរមានការលៃទុកពេលវេលា និងធនធានបន្ថែម សម្រាប់ការវាយតម្លៃផលប៉ះពាល់នៃគម្រោងដែលស្នើឡើង និងគួរធ្វើការពិគ្រោះយោបល់ជាទៀងទាត់ជាមួយសហគមន៍មូលដ្ឋាន។ គួរបង្កើតយន្តការនានាសម្រាប់ការប្រាស្រ័យទាក់ទងជាមួយ

សហគមន៍ ដំណោះស្រាយតាមរយៈសំណាង និងការគ្រប់គ្រងទំនាស់ផងដែរ។

៥.១.១.៥ ចូរធ្វើការវាយតម្លៃពេញលេញអំពីផលប៉ះពាល់នៃការសាងសង់ និងប្រតិបត្តិការសំណើគម្រោង នោះមកលើជនជាតិដើមភាគតិច។ គួរគោរពស្ថានភាពសង្គមនៃជនជាតិដើមភាគតិច។ ចូរធ្វើការវាយតម្លៃផលប៉ះពាល់ជាក់លាក់ ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានមកលើជនជាតិដើមភាគតិច។ ចូរស្វែងរកឲ្យបាននូវការមូលមតិដោយគ្មានការបង្ខិតបង្ខំ ជាមុន និងជាមួយព័ត៌មានគ្រប់គ្រាន់ មុននឹងអនុម័ត និងអនុវត្តវិធានការនានាដែលអាចប៉ះពាល់មកលើពួកគេ។

## ៥.១.២ សិទ្ធិការងារ និងផលប្រយោជន៍

៥.១.២.១ គួរបង្កើតប្រព័ន្ធគ្រប់គ្រងការងារជាក់លាក់សម្រាប់ឧស្សាហកម្មកៅស៊ូ អនុលោមតាមលក្ខខណ្ឌតម្រូវ នៃច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក។ កិច្ចសន្យាការងារ គួរតែបានចុះហត្ថលេខា ដោយផ្អែកលើគោលការណ៍សមធម៌ ដោយចែងច្បាស់ពីលក្ខខណ្ឌអំពីវិធីគណនាប្រាក់បៀវត្សរ៍ និងការបើកប្រាក់បៀវត្សរ៍។ ចូរគោរពសិទ្ធិរបស់និយោជិតក្នុងការបញ្ចប់ការងាររបស់ពួកគេ អនុលោមតាមកិច្ចសន្យា ឬ ច្បាប់។

៥.១.២.២ ត្រូវហាមឃាត់ការពលកម្មកុមារ និងការតម្រូវឲ្យកុមារធ្វើការងារច្រើនហួសហេតុ ឬថែមម៉ោង។ សហគ្រាសត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងច្បាប់ការងារ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនៅថ្នាក់ជាតិ និងនៅពាក់ព័ន្ធ។

៥.១.២.៣ គួរមានការធានាថា ការជួល ការកំណត់មុខតំណែង ការផ្តល់ប្រាក់កម្រៃ ការតម្លើងតួនាទី ការបណ្តុះបណ្តាល ការដាក់ទណ្ឌកម្មនិងការចូលនិវត្តន៍របស់និយោជិត ការបញ្ចប់កិច្ចសន្យា និងការពិចារណាដទៃទៀតបានធ្វើឡើង ដោយផ្អែកតាមកត្តាបរានុមតិ ដោយពុំគិតពីភេទ អាយុ សញ្ជាតិ ជនជាតិ សាសនា ស្ថានភាពអាពាហ៍ពិពាហ៍ ដើមកំណើតនៃជនជាតិភាគតិច និងអត្តសញ្ញាណសង្គមឡើយ។

៥.១.២.៤ គួរមានការធានាថា និយោជិតទាំងអស់មិនត្រូវទទួលទណ្ឌកម្មលើរាងកាយ ឬការវាយប្រហារនៅកន្លែងធ្វើការឡើយ។ ត្រូវទប់ស្កាត់ និងហាមឃាត់រាល់ការធ្វើទុក្ខបុកម្នេញ ឬ ការបំពានលើរាងកាយ ផ្លូវចិត្ត ឬដោយពាក្យសំដីនៅកន្លែងធ្វើការ ដែលរួមទាំង ការបំពានខាងផ្លូវភេទ។ មិនត្រូវអត់ឱនចំពោះសកម្មភាពបំពាននិងការធ្វើទុកបុកម្នេញឡើយ។

៥.១.២.៥ មិនត្រូវប្រើប្រាស់ទម្រង់ណាមួយនៃពលកម្មដោយបង្ខំឡើយ ទោះក្នុងដំណាក់កាលណាមួយនៃផលិតកម្ម។ ក្រុមហ៊ុនមិនត្រូវទទួលយកប្រាក់ ឬ ទ្រព្យផ្ទាល់ខ្លួនរបស់និយោជិត ឬតម្រូវឲ្យពួកគេផ្តល់ការធានាណាមួយ និងមិនអាចដកហូត ឬ យកមករក្សាទុកអត្តសញ្ញាណប័ណ្ណ ឬឯកសារដទៃណាមួយរបស់ពួកគេឡើយ។

៥.១.២.៦ ការទូទាត់ប្រាក់កម្រៃដល់និយោជិត ត្រូវធ្វើឡើង ស្របតាមកិច្ចសន្យាការងារតាមពេលកំណត់

ហើយប្រាក់កម្រៃមិនត្រូវទាបជាងស្តង់ដារអប្បបរមាដែលមាននៅមូលដ្ឋាននៃប្រទេសនោះឡើយ។ ក្នុងករណីអនុវត្តប្រាក់កម្រៃតាមលទ្ធផល ឬតាមបរិមាណដែលលក់ដាច់ សហគ្រាសត្រូវធានាភាពស្របច្បាប់ និងហេតុផលនៃកូតាផលិផល។

៥.១.២.៧ ការបង្កើតសហជីពកម្មករ គួរបានទទួលការគាំទ្រ អនុលោមតាមច្បាប់ពាក់ព័ន្ធ ដើម្បីការពារផលប្រយោជន៍របស់និយោជិត។

៥.១.២.៨ ត្រូវផ្តល់លក្ខខណ្ឌការងារល្អសម្រាប់និយោជិក ដើម្បីការពារសុខភាព និងសុវត្ថិភាពរបស់និយោជិត។ គួរមានការជូនដំណឹងបានច្បាស់លាស់ដល់និយោជិត អំពីហានិភ័យដែលទាក់ទងនឹងសុខភាពនិងសុវត្ថិភាព និងវិធានការបន្ទាន់ដាក់ឲ្យអនុវត្តសម្រាប់ព្រឹត្តិការណ៍ដែលមិនបានរំពឹងទុក។

៥.១.២.៩ គួរផ្តល់បគ្គបណ្តុះបណ្តាលជំនាញ និងការអប់រំបន្ថែមសម្រាប់និយោជិត។ នៅពេលអនុវត្តបាន ត្រូវជួយបង្កើតមូលនិធិវគ្គបណ្តុះបណ្តាល ដើម្បីជួយនិយោជិតរៀបចំផែនការអភិវឌ្ឍន៍អាជីពរបស់ខ្លួន។

៥.១.២.១០ គួរផ្តល់ឲ្យនិយោជិតនូវប្រាក់កម្រៃសមរម្យ និងលក្ខខណ្ឌការងារសមស្រប ដោយពិចារណា និងគាំទ្រគ្រួសារនិយោជិត និងតួនាទីរបស់ពួកគេក្នុងសង្គមផងដែរ។ គួរផ្តល់ការយកចិត្តទុកដាក់ដល់គ្រួសារ និងលើកទឹកចិត្តនិយោជិត ព្រមទាំងធ្វើឲ្យមានតុល្យភាពរវាងការងារនិងរបៀបរស់នៅផងដែរ។

៥.១.២.១១ គួរបង្កើតឲ្យមានមធ្យោបាយសម្រាប់ការប្រាស្រ័យទាក់ទងប្រចាំថ្ងៃ សម្រាប់និយោជិត ដើម្បីធានាថា និយោជិតអាចប្រាស្រ័យទាក់ទង ឬលើកបណ្តឹងទៅថ្នាក់គ្រប់គ្រងក្រុមហ៊ុន អំពីកង្វះអនុលោមភាពនៃទំនុកចិត្ត និងយុត្តិធម៌ និងមិនត្រូវខ្លាចការសងសឹក ដែលរួមទាំង ការភ័យខ្លាចបណ្តេញពីការងារ ឬការដាក់ទណ្ឌកម្មរើសអើងដទៃទៀតផងដែរ។

៥.១.៣ កិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល

ក្រុមហ៊ុនត្រូវគិតគូរគ្រប់ជ្រុងជ្រោយអំពីឥទ្ធិពលផ្ទាល់ និងប្រយោលនៃអង្គការសង្គមស៊ីវិលមកលើគម្រោងស្នើសុំ ធ្វើការអនុវត្តការពិគ្រោះយោបល់ បង្កើតយន្តការប្រាស្រ័យទាំងទាង និងកសាងភាពជាដៃគូសារជីវកម្ម និងភាពជាដៃគូនៅកម្រិតខុសៗគ្នាតាមការចាំបាច់។

## ៥.២ ការទទួលខុសត្រូវខាងបរិស្ថាន

### ៥.២.១ ចំការកៅស៊ូ

៥.២.១.១ ត្រូវរៀបចំផែនការបរិស្ថានពេញលេញសម្រាប់ចំការកៅស៊ូ ដែលរួមទាំង ប៉ុន្តែមិនកំហិតត្រឹមការជ្រើសរើសពូជក្លូនកៅស៊ូសមស្រប កិច្ចការពារប្រភេទសត្វព្រៃ និងរុក្ខជាតិព្រៃដែលមានដោយកម្រនិងជិតផុតពូជ របៀងជីវចម្រុះ តំបន់ទ្រនាប់ព្រៃឈើ/ក្រវាត់ព្រៃឈើ ដើម្បីញែកកន្លែងដាំ ដាច់ចេញពីភូមិ ការ

គ្រប់គ្រងទីជម្រាល គម្រោងអភិរក្សដី និងទឹក និងកាត់បន្ថយការប្រើប្រាស់ថ្នាំគីមី។ ត្រូវធានាឲ្យមានការគោរពគោលការណ៍"តុល្យភាពបាត់បង់ព្រៃឈើសូន្យ" អនុលោមភាពជាមួយច្បាប់និងបទប្បញ្ញត្តិស្តីពីកិច្ចការពារព្រៃឈើ ការពារព្រៃធម្មជាតិ និងហាមឃាត់ការបំផ្លាញព្រៃដើម និងអភិរក្សតំបន់អេកូឡូស៊ីផុយស្រួយ តំបន់ដែលមានគុណតម្លៃខ្ពស់សម្រាប់ការអភិរក្ស និងកន្លែងមានស្តុកកាបូនខ្ពស់។

៥.២.១.២ ចូរប្រើប្រាស់វិធីសមស្របសម្រាប់ការរានឆ្ការដី ដោយផ្អែកលើលក្ខខណ្ឌភូមិសាស្ត្រនៃដី និងប្រភេទដី និងត្រូវបង្កើតប្រព័ន្ធដាំកៅស៊ូឲ្យបានសមស្រប ដោយត្រូវគិតគូរពីលក្ខខណ្ឌនៅមូលដ្ឋាន។ គួរដាំតាមខ្សែរយៈកំពស់សម្រាប់កន្លែងដែលមានចំណោតខ្លាំង កសិ-រុក្ខកម្មជាមួយរចនាសម្ព័ន្ធដើមឈើ+រុក្ខជាតិព្រៃស្បាត+តិណទេស និងគម្របដី ដើម្បីកែលំអជីវចម្រុះដែលបានដាំ ថែរក្សាជីជាតិដី ទប់ស្កាត់ការហូរច្រោះ កាត់បន្ថយកត្តាចង្រៃ និងជំងឺ ពង្រីកជីវចម្រុះ និងជួយដល់មុខងារអេកូឡូស៊ីនៃចំការ។

៥.២.១.៣ ក្នុងករណីមានគ្រោះរាំងស្ងួត ទឹកជំនន់ ព្យុះទីផុង ការប្រឈមនឹងពន្លឺថ្ងៃខ្លាំង ការខូចខាតដោយសារកំណកទឹកសន្សើម និងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរដទៃទៀត ចូរសង់ប្រព័ន្ធដោះទឹក និងអនុវត្តវិធានការទប់ស្កាត់ផ្សេងទៀតដែលមានប្រសិទ្ធភាព សម្រាប់ការដាំនៅតាមចន្លោះ ការប្រមូលយកជ័រនិងកិច្ចការពារពលកម្ម ដើម្បីទប់ស្កាត់ និងកាត់បន្ថយហានិភ័យដែលពាក់ព័ន្ធដទៃទៀត។

៥.២.១.៤ នៅក្នុងប្រព័ន្ធគ្រប់គ្រងចំការ គួរពិចារណាទិដ្ឋភាពនានា ដូចជា ឥទ្ធិពលនៃពន្លឺព្រះអាទិត្យ ការដោះទឹកភ្លៀង ការចៀរជ័រ សុខភាពនិងសុវត្ថិភាពកម្មករ ដើម្បីកាត់បន្ថយហានិភ័យនិងពង្រីកប្រសិទ្ធផល។

៥.២.១.៥ ចំការកៅស៊ូត្រូវតែដាំឡើងវិញ ដោយអនុលោមតាមទម្លាប់ល្អនៃសុវត្ថិកម្ម ដើម្បីធានាតុល្យភាពនៃទំនាក់ទំនងរវាងផលចំណេញ និងការអភិវឌ្ឍដោយចីរភាព។ ដើម្បីជាប្រយោជន៍នៃការស្តារព្រៃឡើងវិញ គេគួរតែដាំកៅស៊ូឡើងវិញនៅក្នុងចំការចាស់ៗ តាមវិធីវិទ្យាសាស្ត្រ និងសមស្រប ដោយប្រើវិធីដាំឆ្លាស់ការដាំបន្ត និងការដាំជារង្វិលជុំ។ ក្នុងករណីមានជំងឺដែលមិនអាចគ្រប់គ្រងបាន គួរពិចារណាអំពីការដាំជារង្វិលជុំសម្រាប់រយៈពេលវែង ឬការស្តារព្រៃឈើឡើងវិញ។

### ៥.២.២ រោងចក្រកែច្នៃកៅស៊ូឆៅ

៥.២.២.១ ត្រូវធានាឲ្យមានធនធានដូចជា វត្ថុធាតុដើមឆៅ សេវាកម្មសាធារណៈ និងមធ្យោបាយដឹកជញ្ជូន និងត្រូវពិចារណាវត្តមានធនធានទឹក ដើម្បីឲ្យរោងចក្រប្រតិបត្តិការបានយ៉ាងមានប្រសិទ្ធភាព។

៥.២.២.២ គួរអនុវត្តវិធីប្រព្រឹត្តកម្មសំអាចសំណល់រាវ និងកែច្នៃសំណល់រាវសម្រាប់ការប្រើប្រាស់ឡើងវិញដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន។

៥.២.២.៣ ត្រូវធ្វើការប្រមូលសំណល់ឧស្ម័ន ប្រព្រឹត្តកម្មសំអាត និងគ្រប់គ្រងការបញ្ចេញចោល ដើម្បីកាត់បន្ថយផលប៉ះពាល់មកលើបរិស្ថានជុំវិញ

៥.២.២.៤ ការបោលសំណល់រឹងត្រូវគោរពតាមលក្ខខណ្ឌតម្រូវខាងបរិស្ថានដែលពាក់ព័ន្ធ ដោយធានាថាពុំមានការបំពុលជាបន្តទៀយ។

៥.២.២.៥ ការស្តុកទុកកៅស៊ូក្នុងឃ្លាំងចែកចេញជាពីរបែប៖ វត្ថុជាតុដើមទៅ និងផលិតផលសម្រេច។ គួរតែបានគ្រប់គ្រងផលប៉ះពាល់នៃការស្តុកទុកក្នុងឃ្លាំងមកលើបរិស្ថាន ដែលរួមទាំង ផលប៉ះពាល់នៃទីលានដាក់វត្ថុជាតុដើម មកលើទីជុំវិញឲ្យមានប្រសិទ្ធភាព ហើយឃ្លាំងគួរតែស្ថិតនៅក្នុងចម្ងាយសមស្របពីកន្លែងតាំងទីលំនៅរបស់ប្រជាជន។

៥.២.២.៦ នៅពេលដែលចាំបាច់ត្រូវជួសជុល ឬពង្រីករោងចក្រចាស់ ប្រការចាំបាច់គឺត្រូវវិភាគប្រសិទ្ធភាពនៃបរិក្ខារ និងសម្បទានានា ធ្វើការវាយតម្លៃផលប៉ះពាល់មកលើបរិស្ថាន និងវិភាគតម្រូវការ និងវត្តមាននៃធនធានខុសៗគ្នា (ដូចជា វត្ថុជាតុដើម ម្សៅ និងការដឹកជញ្ជូន) ដើម្បីធានាប្រតិបត្តិការជាប្រក្រតី។

## ៥.៣ ការទទួលខុសត្រូវខាងសេដ្ឋកិច្ច

### ៥.៣.១ ការជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច

៥.៣.១.១ ត្រូវជម្រុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅក្នុងកន្លែង និងសហគមន៍នានាជុំវិញប្រតិបត្តិការចំការកៅស៊ូ។ តាមរយៈការវិនិយោគនិងសកម្មភាពធុរកិច្ច ត្រូវបង្កើនផលចំណូលសេដ្ឋកិច្ចនៃអង្គភាពដែលធ្វើការវិនិយោគ និងនិយោកជិត និងសហគមន៍មូលដ្ឋាន។ ត្រូវជួយជនក្រីក្រ នៅទូទាំងការអភិវឌ្ឍសហគមន៍។ ត្រូវបង្កើនកាលានុវត្តិភាពមុខរបរ និងរួមចំណែកចំពោះការអភិវឌ្ឍសេដ្ឋកិច្ច។ ជាក់ស្តែង ត្រូវយកចិត្តទុកដាក់ចំពោះផលចំណេញសេដ្ឋកិច្ចសម្រាប់កសិករតូចតាច នៅក្នុងករណីអាចធ្វើបាន អាចផ្តល់ជំនួយបច្ចេកទេស តាមរយៈសកម្មភាពអនុវត្តបង្ហាញ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៃកសិករតូចតាច។

៥.៣.១.២ ត្រូវជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចបរិស្ថាន។ ត្រូវយកចិត្តទុកដាក់ចំពោះផលប៉ះពាល់បរិស្ថាននៃចំការឯកវប្បកម្ម តាមរយៈការវិនិយោគ និងសកម្មភាពធុរកិច្ច។ ត្រូវប្រកាន់យកសេដ្ឋកិច្ចព្រៃឈើចម្រុះ និងគំរូសេដ្ឋកិច្ចបៃតងដទៃទៀត និងគំរូសេដ្ឋកិច្ចវិលជុំ។ ត្រូវចាត់វិធានការសកម្មដែលទាក់ទងនឹងការអភិរក្សដី និងទឹក ការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់គីមី ជីវចម្រុះ កិច្ចការពារព្រៃឈើ និងការប្រើប្រាស់ធនធានឲ្យបានពេញលេញ ដើម្បីកែលំអបរិស្ថានយ៉ាងសកម្ម និងជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចបរិស្ថានៅមូលដ្ឋាន។

៥.៣.១.៣ ចូរកែលំអនវានុវត្តន៍ តាមរយៈការវិនិយោគ និងសកម្មភាពធុរកិច្ច និងជម្រុញការអនុវត្តបច្ចេកវិទ្យាថ្មីៗ ដំណើរការថ្មីៗ និងបរិក្ខារថ្មីៗ។ ចូរកែលំអខ្សែចង្វាក់ផ្គត់ផ្គង់ ដោយផ្តល់កម្លាំងជម្រុញឲ្យមានការអភិវឌ្ឍឧស្សាហកម្មខុសៗគ្នា និងចែករំលែកផលពីនវានុវត្តន៍ ជាមួយអាជ្ញាធរមូលដ្ឋាន ដែលទាក់ទងនឹងឧស្សាហកម្ម និងកសិករតូចតាច។

៥.៣.១៤ ចូររក្សាអនុលោមភាពជាមួយច្បាប់នានានៅក្នុងប្រទេសជាម្ចាស់ផ្ទះ និងកន្លែងប្រតិបត្តិការនានា

និងផ្ទេរទៅតាមពេលវេលា នូវផលចំណេញពីការវិនិយោគ ដើម្បីធានាឲ្យមានផលចំណេញពីការវិនិយោគដើមទុន។ ចូរដាក់ឲ្យអនុវត្តវិធានការនានា ដើម្បីធានាថា ដៃគូក្នុងធុរកិច្ច ធ្វើប្រតិបត្តិការស្របជាមួយច្បាប់ និងបទប្បញ្ញត្តិនានាដែលនៅជាធរមានទាំងអស់ និងគោលការណ៍នៃគោលការណ៍ណែនាំនេះ។

### ៥.៣.២ ការរក្សាទម្លាប់ល្អក្នុងធុរកិច្ច

ត្រូវរក្សាការបញ្ជាទិញសមស្របក្នុងទីផ្សារ និងកំណត់អត្តសញ្ញាណឥរិយាបថផ្តាច់មុខ និងភាពប្រកួតប្រជែងស្លាប់រស់។ល។ ចូរទប់ស្កាត់ និងត្រួតពិនិត្យអំពើសូកប៉ាន់ដែលអាចកើតមាន ឬទម្រង់នានានៃអំពើពុករលួយនៅក្នុងអំឡុងពេលប្រតិបត្តិការ។ ចូរវិភាគទីផ្សារ និងច្បាប់ប្រតិបត្តិការសេដ្ឋកិច្ចតាមបែបវិទ្យាសាស្ត្រ ដើម្បីជួយធានាថា ទីផ្សារប្រតិបត្តិការតាមបែបបទសមស្របនិងជាវិជ្ជមាន។

### ៥.៣.៣ ការបង់ និងទទួលពន្ធ និងអាករនានាស្របតាមច្បាប់

ត្រូវបង់ពន្ធ និងអាករនានា ស្របតាមបទប្បញ្ញត្តិរបស់ប្រទេសនោះ។ ជាក់ស្តែង គួរធ្វើការកត់សំគាល់ថា កៅស៊ូធម្មជាតិ គឺជាកសិផល និងក៏ជាវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មផងដែរ និងក៏ជាផលិតផលហិរញ្ញវត្ថុដែរ។ ក្នុងន័យនេះ វាអាចជាកម្មវត្ថុនៃការបង់ពន្ធ និងអាករនានា ដែលរួមទាំង ពន្ធ និងកម្រៃកសិកម្ម ពន្ធ និងកម្រៃប្រតិបត្តិការសម្រាប់ផលិតផលឧស្សាហកម្ម ពន្ធ និងកម្រៃសម្រាប់ផលិតផលហិរញ្ញវត្ថុ ពន្ធ និងកម្រៃលើការបំពុល។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១. អ្នកដែលបានរួមវិភាគទានចំពោះគោលការណ៍ណែនាំនេះ

ការស្រាវជ្រាវនេះ និងការរៀបចំគោលការណ៍ណែនាំនេះ បានចាត់ចែងដោយសភាពាណិជ្ជកម្មចិនខាងការនាំចូល និងនាំចេញលោហធាតុ រ៉ែ និងគីមី (CCCMC)។ យើងសូមថ្លែងអំណរគុណចំពោះលោក Feng Chen ប្រធានសភា CCCMC និងលោក Zhonghui Liu អនុប្រធានដែលបានផ្តល់ការណែនាំនិងការគាំទ្រ។ ក្រុមការងារស្នូលដែលត្រូវបានប្រគល់ភារៈកិច្ចឲ្យរៀបចំគោលការណ៍ណែនាំនេះ ដឹកនាំដោយលោក Lihui Sun មកពីសភាពាណិជ្ជកម្មចិនខាងផ្នែកនាំចូល និងនាំចេញលោហធាតុ រ៉ែ និងគីមី។ ក្រុមការងារស្នូលនេះមានអ្នកជំនាញការដូចតទៅ (ពុំបានដាក់តាមលំដាប់ឡើយ)៖ លោកស្រី Jiangtao Wu មកពីវិទ្យាស្ថានស្រាវជ្រាវ និងរចនាបថឧស្សាហកម្មកៅស៊ូនៃទីក្រុងប៉េកាំង លោក Jianchu Xu មកពីវិទ្យាស្ថានរុក្ខសាស្ត្រគុនមីង (សភាវិទ្យាសាស្ត្រចិន) លោកស្រី Yufang Su មកពីមជ្ឈមណ្ឌលកសិ-រុក្ខកម្មពិភពលោក លោកស្រី Li Li មកពីសកលវិទ្យាល័យធុរកិច្ចនិងសេដ្ឋកិច្ចអន្តរជាតិ លោក Qiubo Chen មកពីសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន លោក Xiaohui Liang មកពីមជ្ឈមណ្ឌលព័ត៌មានវាយនភណ្ឌចិន លោក Peiyuan Guo និងលោក Hongfu Zhang មកពី Syntao, អ្នកជំនាញការឯករាជ្យមកពីប្រទេសម៉ាឡេស៊ី លោក Sivakumaran និងអ្នកជំនាញការមកពីអង្គការក្លូបលវិតណែស។ ក្រុមអ្នកផ្តល់យោបល់រួមមាន ប្រធានក្រុម និងអ្នកជំនាញការមកពីសមាគមនកៅស៊ូធម្មជាតិចិន វិទ្យាស្ថានទទួលខុសត្រូវសង្គមនៃសាជីវកម្ម Rongzhi នៃទីក្រុងប៉េកាំង ក្រុមឧស្សាហកម្មកៅស៊ូហៃណាន នៃប្រទេសចិន។

## ឧបសម្ព័ន្ធ ២. បច្ចេកស័ព្ទ និងនិយមន័យ

ពិនិត្យពិច័យ

ដំណើរការពេញលេញបែបគិតទុកជាមុនមួយ សម្រាប់កំណត់អត្តសញ្ញាណផលប៉ះពាល់អវិជ្ជមានសង្គម បរិស្ថាន និងសេដ្ឋកិច្ច ដែលមានជាក់ស្តែង និងដែលអាចកើតមាន បណ្តាលពីការសម្រេច និងសកម្មភាពរបស់ស្ថាប័នណាមួយ នៅទូទាំងវដ្តនៃគម្រោង ឬសកម្មភាពរបស់ស្ថាប័ននោះ ក្នុងគោលដៅបញ្ចៀស និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន។

អ្នកពាក់ព័ន្ធ

អ្នកពាក់ព័ន្ធណាមួយនៅក្នុងស្ថាប័នមួយ គឺជាក្រុម ឬ បុគ្គល ដែលអាចបង្ក ឬរងការប៉ះពាល់ដោយសមិទ្ធផលនៃគោលបំណងរបស់ស្ថាប័ននោះ។

កម្លាំងជម្រុញ

"កម្លាំងជម្រុញ" គឺជាភាពខ្លាំងដែលមានអំណាចក្នុងការធ្វើឲ្យមានឥទ្ធិពលមកលើមនុស្សដទៃទៀត។ វាមានន័យថាជាសមត្ថភាពក្នុងការកែប្រែឥរិយាបថមិនត្រឹមត្រូវដែលបង្កដោយ ឬ ដែលកើនឡើងដោយដៃគូក្នុងធុរកិច្ច។

ប្រព័ន្ធដាំ

ប្រព័ន្ធចម្រុះមួយដែលមានរចនាសម្ព័ន្ធដាំកៅស៊ូធម្មជាតិ ការចាត់ចែង ប្រព័ន្ធធ្វើឲ្យលូតលាស់ និងវិធីដាំ។ វិធីដាំ រួមមាន ការដាំជារង្វិលជុំ ការដាំបន្ត ការដាំឆ្លាស់ ការដាំបណ្តាក់ពេល ការដាំចម្រុះ និងការដាំតែមួយមុខ។ ប្រព័ន្ធដាំសមស្រប គួរតែបានធ្វើឡើងដើម្បីឲ្យមានការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ដូចជា ពន្លឺ និងកំដៅ ចំហាយទឹក ដី និងពលកម្ម និងគួរតែអាចទទួលបានអត្ថប្រយោជន៍ខ្ពស់បំផុតខាងអេកូឡូស៊ី និងសង្គមសេដ្ឋកិច្ច ពីផលិតកម្មកៅស៊ូធម្មជាតិ នៅក្រោមលក្ខខណ្ឌនៅនឹងកន្លែង។ វាមានប្រយោជន៍ក្នុងការសម្របសម្រួលដំណាំខុសៗគ្នា នៅក្នុងការដាំ ដែលរួមទាំង កៅស៊ូធម្មជាតិ ដំណាំសេដ្ឋកិច្ច និងសត្វចិញ្ចឹម ទាំងដំណាំដែលអាចដាំលើដី និងដំណាំសម្រាប់កែលំអដី ដើម្បីជម្រុញការអភិវឌ្ឍពេញលេញនៃកៅស៊ូធម្មជាតិ ក៏ដូចជា ការចិញ្ចឹមសត្វ កសិកម្ម និងព្រៃឈើ។

គោលដៅអភិវឌ្ឍន៍ដោយចីរភាពនៃអ.ស.ប (SDGs)

នៅក្នុងកិច្ចប្រជុំកំពូលអ.ស.ប ស្តីពីការអភិវឌ្ឍដោយចីរភាព កាលពីខែកញ្ញាឆ្នាំ ២០១៥ របៀបវារៈអភិវឌ្ឍន៍ដោយចីរភាពថ្មី ត្រូវបានអនុម័តដោយសមាជិកចំនួន ១៩៣ នៃអ.ស.ប ដែលចែងអំពីគោលដៅអភិវឌ្ឍ

ន៍ដោយចីរភាព (SDGs) ចំនួន ១៧ និងចំណុចដៅចំនួន ១៦៩។ SDGs ចូលជាធរមាននៅថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៦ ហើយវានឹងបន្តផ្តល់ការណែនាំសម្រាប់គោលនយោបាយអភិវឌ្ឍន៍ និងផ្តល់មូលនិធិសម្រាប់អំឡុងឆ្នាំ ២០១៦-២០៣០ បន្ទាប់ពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ SDGs និងចំណុចដៅ មានសុពលភាពសម្រាប់ការអនុវត្តជាសកលលើពិភពលោក ដោយគិតបញ្ចូលស្ថានភាពជាក់ស្តែងនៅថ្នាក់ជាតិ សមត្ថភាព និងកម្រិតនៃការអភិវឌ្ឍ និងការគោរពគោលនយោបាយ និងអាទិភាពជាតិ។ វាមានគោលដៅសម្រេចបានទិដ្ឋភាពបីនៃការអភិវឌ្ឍដោយចីរភាព - កំណើនសេដ្ឋកិច្ច និរន្តរភាពបរិស្ថាន និងបរិយាប័ន្នសង្គម។

ជនជាតិដើមភាគតិច

ដោយសារតែភាពចម្រុះនៃជនជាតិដើមភាគតិច ស្ថាប័ននៃប្រព័ន្ធអ.ស.បនៅពុំទាន់បានអនុម័តនិយមន័យផ្លូវការមួយអំពី"ជនជាតិដើមភាគតិច"ឡើយ។ ជាជំនួស ប្រព័ន្ធនេះបានបង្កើនការយល់ដឹងទំនើបមួយនៃបច្ចេកស័ព្ទនេះដោយផ្អែកលើចំណុចនានាដូចតទៅ៖

- ស្វ័យអត្តសញ្ញាណកម្ម ជាជនជាតិដើមភាគតិចនៅកម្រិតបុគ្គល និង
- ការទទួលយកដោយសហគមន៍ ជាសមាជិករបស់ពួកគេ
- ប្រវត្តិហូរហែរជាមួយសង្គមនៅមុនសម័យអាណានិគមនិង/ឬមុនជនចំណូលស្រុកមកតាំងទីលំនៅ
- ចំណងទាក់ទងជិតស្និទ្ធទៅនឹងដែនដី និងធនធានធម្មជាតិនៅជុំវិញនោះ
- ប្រព័ន្ធសង្គម សេដ្ឋកិច្ច និងនយោបាយដាច់ដោយឡែក
- ភាសា វប្បធម៌ និងជំនឿខុសប្លែកពីគេ
- បង្កើតជាក្រុមភាគតិចនៅក្នុងសង្គម
- សម្រេចថែរក្សា និងបង្កើតបរិស្ថាននៃបុព្វបុរសរបស់ពួកគេ និង
- ប្រព័ន្ធដែលមានប្រជាជន និងសហគមន៍ខុសប្លែកពីគេ។

ខ្សែចង្វាក់តម្លៃ

និយមន័យពី ISO26000 ចែងថា៖

លំដាប់លំដោយនៃសកម្មភាពទាំងមូល ឬ ផ្នែកនានាដែលផ្តល់ ឬ ទទួលតម្លៃក្នុងទម្រង់ជាផលិតផល (2.15) ឬសេវា (2.16)

សំគាល់ ១៖ ភាគីនានាដែលផ្តល់តម្លៃ រួមមាន អ្នកផ្គត់ផ្គង់ កម្មករមកពីប្រភពខាងក្រៅ (2.27), អ្នកម៉ៅការ និងអ្នកដទៃទៀត

សំគាល់ ២៖ ភាគីនានាដែលទទួលតម្លៃ រួមមាន អតិថិជន (2.3), អ្នកប្រើប្រាស់ (2.2), អ្នកទិញ សមាជិក

និងអ្នកប្រើប្រាស់ដទៃទៀត

ខ្សែចង្វាក់ឧស្សាហកម្ម
ទំនាក់ទំនងមួយបែបនៃបច្ចេកទេស និងសេដ្ឋកិច្ច រវាងវិស័យឧស្សាហកម្មនានា។ ទំនាក់ទំនងរវាងខ្សែចង្វាក់មួយ បង្កើតជាមូលដ្ឋាននៃទំនាក់ទំនងសមហេតុផលជាក់លាក់ និងទម្រង់រូបវន្តនិងពេលវេលា។

យន្តការបណ្តឹងសារទុក្ខ
នេះជាដំណើរការក្រៅប្រព័ន្ធតុលាការ ដែលផ្តល់មធ្យោបាយផ្លូវការ ដែលតាមរយៈមធ្យោបាយនេះ បុគ្គល ឬ ក្រុមនានាអាចមានលទ្ធភាពលើកកង្វល់របស់ខ្លួន និងស្វែងរកសំណងសម្រាប់ផលប៉ះពាល់ ដោយសារតែប្រតិបត្តិការនៃធុរកិច្ចនោះ។ យន្តការបណ្តឹងសារទុក្ខ អាចប្រើប្រាស់មជ្ឈត្តវិនិច្ឆ័យ ការសន្ទនា ឬ នីតិវិធីដទៃទៀត ដើម្បីបន្សាំទៅតាមសារតាវប្បធម៌ខុសៗគ្នា និងដើម្បីសម្រួលសម្រាប់ការទាមទារខុសៗគ្នា។ អ.ស.ប ជឿថា "យន្តការបណ្តឹងសារទុក្ខ"មួយដែលមានប្រសិទ្ធភាព ត្រូវតែស្របច្បាប់ អាចប្រើប្រាស់បាន អាចព្យាករណ៍បាន មានសមធម៌ តម្លាភាព សមស្របជាមួយសិទ្ធិ និងជាប្រភពមួយនៃការបន្តរៀនសូត្រ។

តុល្យភាពនៃការបាត់បង់ព្រៃឈើសូន្យ
អវត្តមានការបាត់បង់ព្រៃឈើនៅគ្រប់ដំណាក់កាល ត្រូវបានប្តេជ្ញា និងអនុវត្តដោយក្រុមហ៊ុនអភិវឌ្ឍន៍ នៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ លើការរានឆ្ការដីសម្រាប់អភិវឌ្ឍន៍ចំការកៅស៊ូ ឬ សម្រាប់ការអភិវឌ្ឍន៍ដំណាំចំការផ្សេងទៀត ក្នុងគោលបំណងអភិរក្សព្រៃឈើធម្មជាតិ។

ការអភិវឌ្ឍជាបរិយាប័ន្ន
ការអភិវឌ្ឍជាបរិយាប័ន្ន រួមបញ្ចូលស្តង់ដារ និងគោលការណ៍សិទ្ធិមនុស្សៈ ការចូលរួម គ្មានការរើសអើង និងគណនេយ្យភាព។ ការអភិវឌ្ឍអាចមានបរិយាប័ន្ន និង អាចកាត់បន្ថយភាពក្រីក្រ ប្រសិនបើមនុស្សគ្រប់ក្រុមរួមចំណែកបង្កើតកាលានុវត្តភាព ចែករំលែកផលចំណេញពីការអភិវឌ្ឍ និងចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេច។

កន្លែងមានតម្លៃខ្ពស់សម្រាប់ការអភិរក្ស (HCV)
កន្លែងដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្ស (HCVAs) គឺជាកន្លែងព្រៃឈើ ដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្សមួយឬច្រើនដូចតទៅ៖ (១) កន្លែងដែលមានការប្រមូលផ្តុំយ៉ាងច្រើននៅថ្នាក់ពិភពលោក តំបន់ ឬ ថ្នាក់ជាតិ នូវជីវចម្រុះដែលមានតម្លៃសម្រាប់ការអភិរក្ស(ដូចជាប្រភេទពូជដែលមានតែក្នុងមូលដ្ឋាន ប្រភេទជិតផុតពូជ ទីជម្រក) (២)កន្លែងដែលមានតំបន់ទេសភាពព្រៃឈើយ៉ាងច្រើនដែលមានតម្លៃខ្ពស់នៅ

កម្រិតពិភពលោក តំបន់ ឬថ្នាក់ជាតិ ដែលក្នុងនោះមាន ឬ ផ្សំដោយឯកត្តានៃការគ្រប់គ្រង មានឯកត្តៈក្នុងចំនួនច្រើនសមស្រប (ទោះបីមិនមែនគ្រប់ប្រភេទទាំងអស់សុទ្ធតែកើតមានដោយធម្មជាតិនៅទីនោះក៏ដោយ) បានកើតមានតាមរបាយ និងភាពសំបូរបែបដោយធម្មជាតិ ៣. កន្លែងនានាដែលក្នុងនោះមានប្រភេទកម្រ រងការគំរាមកំហែង ឬ ប្រព័ន្ធអេកូឡូស៊ីជិតបាត់បង់ ៤. កន្លែងនានាដែលផ្តល់សេវាជាមូលដ្ឋានរបស់ធម្មជាតិដែលស្ថិតក្នុងស្ថានភាពផុយស្រួយបំផុត (ដូចជា កិច្ចការពារទីជម្រាល ការគ្រប់គ្រងការហូរច្រោះ) ៥. កន្លែងដែលមានសារៈសំខាន់សម្រាប់ឆ្លើយតបនឹងតម្រូវការជាមូលដ្ឋានរបស់សហគមន៍មូលដ្ឋាន (ដូចជា សម្រាប់ការចិញ្ចឹមជីវិតជាមូលដ្ឋាន សុខភាព) ឬ ៦. កន្លែងដែលសំខាន់ចំពោះអត្តសញ្ញាណវប្បធម៌ប្រពៃណីរបស់សហគមន៍មូលដ្ឋាន។សារៈសំខាន់ ដោយសារតម្លៃខ្ពស់ខាងជីវសាស្ត្រ អេកូឡូស៊ីសង្គម ឬ វប្បធម៌។ កន្លែងទាំងនេះ ត្រូវតែបានគ្រប់គ្រងសមស្រប ដើម្បីថែរក្សា ឬ ពង្រីកគុណតម្លៃដែលបានកំណត់អត្តសញ្ញាណទាំងនោះ។

កន្លែងដែលមានស្តុកកាបូនកម្រិតខ្ពស់ (HCS)
កន្លែងដែលមានស្តុកកាបូនកម្រិតខ្ពស់ គឺដែនដីព្រៃឈើនានាដែលបានកំណត់អត្តសញ្ញាណដោយប្រើប្រាស់អភិក្រម HCS។ អភិក្រមដែលត្រូវកំណត់អត្តសញ្ញាណសម្រាប់កិច្ចការពារពីការបំប្លែងសម្រាប់បង្កើតចំការកៅស៊ូ។ អភិក្រម HCS អាចបង្ហាញភាពខុសគ្នានៃទីកន្លែងដែលស្តុកកាបូនមានកម្រិតខ្ពស់ (ពោលគឺព្រៃឈើ) ធៀបនឹងកន្លែងរេចរឹលនានា ដែលមានកាបូន និងជីវចម្រុះកម្រិតតិចជាង។ ដោយប្រើប្រាស់ GIS និងព័ត៌មានពីផ្កាយរណប អភិក្រម HCS បែងចែកព្រៃឈើជាស្រទាប់ ទៅតាមទីកន្លែងនានាដែលចាត់ជាប្រាំមួយថ្នាក់៖ (ព្រៃឈើមានដង់ស៊ីតេខ្ពស់ ព្រៃដែលមានដង់ស៊ីតេខ្ពស់មធ្យម ព្រៃឈើដែលមានដង់ស៊ីតេទាប ព្រៃឈើទើបលូតលាស់ឡើងវិញ ព្រៃស្បាត និងទីវាល) ដែលជំពូកនីមួយៗទាំងនេះ ត្រូវបានផ្ទៀងផ្ទាត់ តាមរយៈការកែតម្រូវ ធៀបនឹងតួលេខប៉ាន់ស្មានស្តុកកាបូននៅក្នុងជីវម៉ាសដើមឈើលើផ្ទៃដី។ អភិក្រម HCS អាចបង្ហាញភាពខុសគ្នានៃកន្លែងនានាដែលមានស្តុកកាបូនខ្ពស់ (ពោលគឺ ព្រៃឈើ) ធៀបនឹងកន្លែងរេចរឹលនានា ដែលមានកាបូន និង ជីវចម្រុះក្នុងអត្រាទាប។ ដីធ្លីរេចរឹលដែលមានដុះព្រៃស្បាត និងទីវាលចំហ ត្រូវបានចាត់ទុកថាសមស្របសម្រាប់ការបង្កើតចំការកៅស៊ូ ចំណែកកន្លែងដទៃទៀត ដូចជាកន្លែង HCS ត្រូវស្ថិតក្រោមកិច្ចការពារ។

ជីវចម្រុះ
ពាក្យបំប្រួញសម្រាប់"នានាភាពនៃជីវសាស្ត្រ" ជាទូទៅ ជីវចម្រុះសំដៅលើនានាភាព និងវិសមរូបនៃសារពាង្គកាយមានជីវិតទាំងអស់ (ដែលរួមទាំង សត្វ រុក្ខជាតិ និងមីក្រូសារពាង្គកាយ) ភាពចម្រុះខាងសេនេទិក និងភាពស្មុគស្មាញនៃអេកូឡូស៊ីដែលពាក់ព័ន្ធ នៅក្នុងវិសាលភាពនៃទីកន្លែង និងក្នុងកាលវេលាមួយជាក់

ស្តែង។ តាមធម្មតា វាពាក់ព័ន្ធនឹងភាពចម្រុះនៃសេនេទិក ប្រភេទ ជាពិសេស នានាភាពនៃសេនេទិក និងភាពចម្រុះនៃប្រភេទ និងភាពចម្រុះនៃប្រព័ន្ធអេកូឡូស៊ី។

របៀងជីវចម្រុះ
តំបន់រុក្ខជាតិ ដែលផ្តល់សេវាអេកូឡូស៊ី អត្ថប្រយោជន៍សម្រាប់សត្វ និងរុក្ខជាតិ ក្នុងការចល័តដោយសេរី ផ្តល់ភាពតជាប់គ្នារវាងប្រព័ន្ធអេកូឡូស៊ីនិងទីជម្រកដែលខូចខាត ទប់ស្កាត់ភាពនៅដាច់គ្នានៃប្រភេទសត្វ និងរុក្ខជាតិ និងជានាការថែរក្សាជីវចម្រុះ។

ការរៀបចំផែនការប្រើប្រាស់ដី
ការរៀបចំផែនការប្រើប្រាស់ដី សំដៅលើដំណើរការមួយដែល តាមរយៈស្ថាប័ន និងនៅក្នុងដែនដីរបស់ខ្លួន សង្គមធ្វើការសម្រេចអំពីទីកន្លែងដែលសកម្មភាពសេដ្ឋកិច្ចសង្គមខុសៗគ្នា ដូចជា កសិកម្ម ការតាំងលំនៅស្ថាន ឧស្សាហកម្ម ការលំហែកំសាន្ត និងពាណិជ្ជកម្ម គួរតែអាចអនុញ្ញាតឲ្យអនុវត្តបាន។ ចំណុចនេះរាប់បញ្ចូល កិច្ចការពារកន្លែងដែលបានកំណត់ជាមុនមិនឲ្យមានការអភិវឌ្ឍ ដោយសារតែហេតុផលខាងបរិស្ថាន វប្បធម៌ ប្រវត្តិសាស្ត្រ ឬ ហេតុផលប្រហែលគ្នានេះ និងការបង្កើតមាត្រានានាដែលត្រួតកំហិតលើប្រភេទនៃសកម្មភាពអភិវឌ្ឍន៍។

ចំការកៅស៊ូចាស់ៗ
ចំការកៅស៊ូចាស់ៗ គឺជាចំការដែលមានអាយុចំណាស់មកហើយ ដែលបានរងការធ្វើអាជីវកម្មចៀរជ័រកៅស៊ូអស់រយៈពេលជាច្រើនឆ្នាំរួចមកហើយ និងទិន្នផលជ័រពីចំការនោះបង្ហាញពីការថយចុះជាក់ស្តែង។ ចំការកៅស៊ូចាស់ៗ ត្រូវតែជាកម្មវត្ថុនៃការដាំឡើងវិញ នៅពេលដែលទិន្នផលជ័រក្នុងមួយហិកតាមានតិចជាង ៦០% នៃទិន្នផលជាមធ្យមនៃក្លូនដូចគ្នានេះនៅក្នុងទីតាំងដូចគ្នា។

ការដាំឡើងវិញ
ការដាំឡើងវិញ គឺជាការអនុវត្តនៅក្នុងចំការកៅស៊ូ ដែលក្នុងនោះ ដើមកៅស៊ូឈរ ត្រូវបានផ្តួលរំលំ មុននឹងដាំឡើងវិញដោយប្រើប្រាស់ពូជក្លូនដែលល្អជាងមុន។ ចំការកៅស៊ូដែលដាំឡើងវិញ បានបង្កើតឲ្យមានកៅស៊ូថ្មី ឬចំការថ្មីនៃកៅស៊ូដាំឡើងវិញ។

ស្តង់ដារប្រាក់បៀវត្សរ៍អប្បបរមា
សំដៅលើបរិមាណអប្បបរមានៃលាភការដែលនិយោជកម្នាក់ត្រូវបង់ជាកម្រៃសម្រាប់ការងារដែលបានអនុវត្ត ក្នុងអំឡុងពេលធ្វើការស្របតាមច្បាប់ ឬអំឡុងពេលការងារដែលមានចែងនៅក្នុងកិច្ចសន្យាការងារ។

សំដៅលើលាភការអប្បបរមាសម្រាប់ការងារដែលអង្គភាពជាអ្នកជួលត្រូវបង់ទៅតាមច្បាប់ ក្នុងករណីដែលពលករបានធ្វើពលកម្មជាធម្មតា តាមចំនួនម៉ោងធ្វើការដូចមានចែងក្នុងច្បាប់ស្តីពីចំនួនម៉ោងធ្វើការ ឬ កិច្ចសន្យាការងារដែលបានព្រមព្រៀងគ្នាស្របតាមច្បាប់។

ពលកម្មដោយបង្ខំ
គ្រប់ការងារ ឬ សេវាដែលតម្រូវឲ្យបុគ្គលណាម្នាក់ធ្វើ នៅក្រោមការគំរាមកំហែងដាក់ទណ្ឌកម្ម និងដែលសម្រាប់ការងារនោះ បុគ្គលនោះពុំបានធ្វើដោយស្ម័គ្រចិត្តឡើយ។

ពលកម្មកុមារ
បុគ្គលណាម្នាក់ដែលមានអាយុក្រោម ១៦ឆ្នាំ ត្រូវបានសហគ្រាសណាមួយជួល ឬ កេណ្ឌឲ្យធ្វើការនៅក្នុងសកម្មភាពមុខរបរណាមួយ ឬ ដែលផ្តល់សេវាជាថ្នូរនឹងប្រាក់កម្រៃ។ ប្រសិនបើច្បាប់ក្នុងមូលដ្ឋានចែងថាកម្រិតអប្បបរមានៃអាយុធ្វើការគឺ ១៤ ឬ ១៥ឆ្នាំ ហើយប្រការនេះស្របគ្នាជាមួយមាត្រានានានៃអនុសញ្ញាង្គការពលកម្មអន្តរជាតិលេខ ១៣៨ ដែលទាក់ទងនឹងអាយុអប្បបរមាសម្រាប់ការទទួលឲ្យចូលធ្វើការងារ អាយុណាមួយដែលទាបជាងត្រូវមានសុពលភាព។

ការមូលមតិដែលគ្មានការបង្ខំ ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ (FPIC)
អង្គការពលកម្មអន្តរជាតិ (ILO) ឲ្យនិយមន័យ FPIC ថាជាសិទ្ធិរបស់សហគមន៍ "ក្នុងការអនុវត្តអំណាចត្រួតត្រា ក្នុងវិសាលភាពដែលអាចធ្វើទៅបាន លើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ខ្លួន"។ ជាមួយក្របខ័ណ្ឌនៃគោលការណ៍ FPIC សហគ្រាសនានាត្រូវពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ដែលអាចរងការប៉ះពាល់ដោយសារប្រតិបត្តិការរបស់ខ្លួន។ គោលការណ៍ណែនាំស្ម័គ្រចិត្តនៃអង្គការស្បៀង និងកសិកម្មសហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើកម្មសិទ្ធិដី ជលផល និងព្រៃឈើ ក្នុងបរិបទនៃសន្តិសុខស្បៀង ឲ្យនិយមន័យដំណើរការនៃការពិគ្រោះយោបល់ និងការចូលរួមថាជា "ការពាក់ព័ន្ធជាមួយ និងការស្វែងរកការគាំទ្រពីអ្នកទាំងឡាយណាដែលមានសិទ្ធិស្របច្បាប់ អាចរងការប៉ះពាល់ដោយការសម្រេចនានា នៅមុនពេលការសម្រេចនោះធ្វើឡើង និងជាការឆ្លើយតបទៅនឹងវិភាគទានរបស់ពួកគេ ដោយពិចារណាផងដែរនូវអតុល្យភាពអំណាចនាពេលបច្ចុប្បន្ន រវាងភាគីខុសៗគ្នា និងការធានាឲ្យមានការចូលរួមយ៉ាងសកម្ម គ្មានការបង្ខិតបង្ខំ យ៉ាងមានប្រសិទ្ធភាព ប្រកបដោយអត្ថន័យ និងជាមួយព័ត៌មានគ្រប់គ្រាន់ពីបុគ្គល និងក្រុមនានា ដែលពាក់ព័ន្ធនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច"។

## ឧបសម្ព័ន្ធ ៣. ឯកសារយោង អនុសញ្ញាអន្តរជាតិ និងស្តង់ដារពាក់ព័ន្ធនានា

ស្តង់ដារពាក់ព័ន្ធ គោលការណ៍ណែនាំ និងឯកសារយោងនានា


[1] អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ, គោលការណ៍ណែនាំស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចលើកម្មសិទ្ធិដី ជលផល និងព្រៃឈើ ក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ, ឆ្នាំ ២០១២។

[2] FAO, OECD. សេចក្តីណែនាំនៃ FAO-OECD សម្រាប់ខ្សែចង្វាក់ផ្គត់ផ្គង់កសិកម្មប្រកបដោយការទទួលខុសត្រូវ។ ឆ្នាំ ២០១៦

[3] សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC). ស្តង់ដារគុណផលសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម (ជាពិសេសស្តង់ដារ 1, 5, 6, 7)។ ឆ្នាំ ២០១២

[4] អង្គការអន្តរជាតិសម្រាប់បមាណីយកម្ម។ ISO 26000 មគ្គុទេសក៍ការទទួលខុសត្រូវសង្គម។ ឆ្នាំ ២០១០

[5] កិច្ចប្រជុំតុមូលស្តីពីនិរន្តរភាពដូងប្រេង។ RSPO P&C សម្រាប់ផលិតកម្មដូងប្រេងដោយនិរន្តរភាព។ 2013.

[6] កិច្ចប្រជុំតុមូលស្តីពីនិរន្តរភាពដូងប្រេង។ RSPO នីតិវិធីថ្មីសម្រាប់ការដាំ (NPP)។ ២០១៥។

[7] កិច្ចប្រជុំតុមូលស្តីពីនិរន្តរភាពដូងប្រេង។ RSPO ប្រព័ន្ធចេញវិញ្ញាបនបត្រ។ ២០០៧។

[8] ក្រុមប្រឹក្សាថែរក្សាព្រៃឈើ។ គោលការណ៍ និងលក្ខណៈវិនិច្ឆ័យរបស់ FSC សម្រាប់ការថែរក្សាព្រៃឈើ។ FSC-STD-01-001. Version 4.0. 1996.

[9] បណ្តាញកសិកម្មនិរន្តរភាព។ ស្តង់ដារកសិកម្មនិរន្តរភាព។ Version 4. 2010.

[10] FAO មជ្ឈមណ្ឌលវិនិយោគ។ គោលការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ N0.1. 1999.

[11] FAO. ក្រមអន្តរជាតិសម្រាប់ការអនុវត្តលើការចែកចាយ និងប្រើប្រាស់ថ្នាំគីមីកសិកម្ម។ 2003.

[12] HCS ក្រុមដឹកនាំ, Eds. ឧបករណ៍ HCS៖ អភិក្រមស្តុកកាបូនកម្រិតខ្ពស់ - គ្មានការបាត់បង់ព្រៃឈើនៅក្នុងការអនុវត្តជាក់ស្តែង។ Version 1.0. 2015.

[13] FAO. កិចផ្តួចផ្តើបាត់បង់ព្រៃឈើសូន្យ និងផលប៉ះពាល់របស់វាមកលើខ្សែចង្វាក់ផ្គត់ផ្គង់ផលិតផល។ ២០១៧។

[14] ក្រុមនវានុវត្តិដូងប្រេង។ សូចនាករសវនកម្ម។ 2014.

[15] ពលកម្មដោយគ្មានការបង្ខំ និងត្រឹមត្រូវ។ សេចក្តីណែនាំអំពីគោលការណ៍ និងការអនុវត្ត។ ២០១៥។

[16] OECD. សេចក្តីណែនាំអំពីការពិនិត្យពិច័យសម្រាប់ខ្សែចង្វាក់ផ្គត់ផ្គង់ដោយការទទួលខុសត្រូវលើរ៉ែមកពីតំបន់មានជម្លោះ និងតំបន់មានហានិភ័យខ្ពស់។ 2nd Edition. 2014.

[17] CCCMC. គោលការណ៍ណែនាំសម្រាប់ការទទួលខុសត្រូវសង្គមក្នុងការវិនិយោគលើការធ្វើអាជីវកម្មរ៉ែ។ ២០១៥។

[18] ស្តង់ដារឧស្សាហកម្មនៃក្រសួងកសិកម្ម។ សេចក្តីពិស្តារបច្ចេកទេសសម្រាប់ដំណាំកៅស៊ូ ( NY/T 221-2006)។ ២០០៦។
[19] វិធានសម្រាប់ការអនុវត្តសេចក្តីពិស្តារបច្ចេកទេសសម្រាប់ដំណាំកៅស៊ូនៅខេត្តយុនណាន។ ២០០៣
[20] សេចក្តីពីស្តារបច្ចេកទេសសម្រាប់ការបង្កើតចំការកៅស៊ូដែលមានមេត្រីភាពបរិស្ថាន។
[21] ISO 14001:2015 - ប្រព័ន្ធគ្រប់គ្រងបរិស្ថាន។ 2015.
[22] OHSAS 18001: 2007 បទប្បញ្ញត្តិស្តីពីសុខភាពក្នុងមុខរបរ និងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព។ 2007.
[23] កិច្ចផ្តួចផ្តើមរាយការណ៍ពិភពលោក។ គោលការណ៍ណែនាំរាយការណ៍ពីនិរន្តរភាព (G4). 2013.

អនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ

[1] អ.ស.ប. របៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាព។ ២០១៥
[2] អ.ស.ប។ គោលការណ៍នាំមុខស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស។ ២០១១
[3] ក្រុមប្រឹក្សាសិទ្ធិមនុស្សអ.ស.ប។ អនុសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ ១៩៦៦
[4] ក្រុមប្រឹក្សាសិទ្ធិមនុស្សអ.ស.ប។ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ។ ១៩៦៦ (ចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦)
[5] អ.ស.ប។ អនុសញ្ញាស្តីពីជីវចម្រុះ។ ១៩៩២
[6] អ.ស.ប។ អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ ១៩៩២
[7]អ.ស.ប។ កិច្ចព្រមព្រៀងប៉ារីស។ ២០១៥
[8] អនុសញ្ញាស្តីពីតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ ជាពិសេសជាទីជម្រកសត្វស្លាបទឹក។ ១៩៧១
[9] អ.ស.ប។ អនុសញ្ញាក្រុងវៀនអំពីច្បាប់ស្តីពីសន្ធិសញ្ញា។ ១៩៧១
[10] អ.ស.ប។ អនុសញ្ញាសហប្រជាជាតិប្រយុទ្ធប្រឆាំងរហោស្ថានកម្ម។ ១៩៩២
[11] អ.ស.ប។ សេចក្តីថ្លែងការណ៍សាកលស្តីពីសិទ្ធិមនុស្ស។ ១៩៤៨
[12] អ.ស.ប។ អនុសញ្ញាស្តីពីជនជាតិដើម និងកុលសម្ព័ន្ធ។ ១៩៨៩
[13] អ.ស.ប។ សេចក្តីប្រកាសនៃអ.ស.ប ស្តីពីសិទ្ធិជនជាតិដើមភាគតិច។ ២០០៦
[14] អ.ស.ប។ គោលការណ៍នាំមុខនៃអ.ស.ប ស្តពីធុរកិច្ច និងសិទ្ធិមនុស្ស។ ២០១១
[15] គណៈកម្មាធិការស្តីពីសន្តិសុខស្បៀង។ គោលការណ៍សម្រាប់ការវិនិយោគប្រកបដោយការទទួលខុសត្រូវលើកសិកម្ម និងប្រព័ន្ធស្បៀង។ ២០១៤
[16] អ.ស.ប។ អនុសញ្ញាប្រឆាំងអំពើពុករលួយ។ ២០០៥
[17] អនុសញ្ញា ILO៖ អនុសញ្ញាស្តីពីការឈប់សម្រាកប្រចាំសប្តាហ៍ (ក្នុងឧស្សាហកម្ម) (No. 14). 1921.
[18] អនុសញ្ញាILO ៖ អនុសញ្ញាស្តីពីការកំណត់ប្រាក់កម្រៃអប្បបរមា (No. 26). 1928.
[19] អនុសញ្ញាILO ៖ អនុសញ្ញាស្តីពីអាយុអប្បបរមា (ឧស្សាហកម្ម) (No. 59, revised). 1937.
[20] អនុសញ្ញា ILO ៖ អនុសញ្ញាស្តីពីលាភការស្មើគ្នា (No. 100). 1951.
[21] អនុសញ្ញា ILO ៖ អនុសញ្ញាស្តីពីការរើសអើង (មុខរបរ និងអាជីព (No. 111). 1958.
[22] អនុសញ្ញា ILO ៖ អនុសញ្ញាស្តីពីគោលនយោបាយមុខរបរ (No. 122). 1964.
[23] អនុសញ្ញា ILO ៖ អាយុអប្បបរមាសម្រាប់មុខរបរ (No. 138). 1973.
[24] អនុសញ្ញា ILO ៖ អនុសញ្ញាស្តីពីការពិគ្រោះយោបល់បីភាគី (ស្តង់ដារពលកម្មអន្តរជាតិ) (No. 144). 1976.

[25] អនុសញ្ញា ILO ៖ អនុសញ្ញាស្តីពីសុវត្ថិភាពក្នុងការងារ និងសុខភាព (No. 155). 1981.
[26] អនុសញ្ញា ILO ៖ អនុសញ្ញាស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ (No. 182). 1999.
[27] អ.ស.ប។ អនុសញ្ញាស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី។ ១៩៧៩
[28] អ.ស.ប។ អនុសញ្ញាស្តីពីសិទ្ធិកុមារ។ ១៩៨៩
[29] អ.ស.ប។ អនុសញ្ញាស្តីពីកិច្ចគាំពារសិទ្ធិកម្មករចំណាកស្រុក និងគ្រួសារ។ ១៩៩០

## ឧបសម្ព័ន្ធ ៤. សេចក្តីថ្លែងអំណរគុណ

ស្ថាប័នរដ្ឋាភិបាល
ក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន
រដ្ឋបាលព្រៃឈើរដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន
ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស
គណៈកម្មការអភិវឌ្ឍន៍ និងកែទម្រង់ជាតិនៃប្រទេសចិន

វិទ្យាស្ថានស្រាវជ្រាវ
វិទ្យាស្ថានស្រាវជ្រាវ និងរចនាបថសម្រាប់ឧស្សាហកម្មកៅស៊ូក្រុងប៉េកាំង
វិទ្យាស្ថានរុក្ខសាស្ត្រគុនមិញ ( សភាវិទ្យាសាស្ត្រចិន )
មជ្ឈមណ្ឌលកសិ-រុក្ខកម្មពិភពលោក
សកលវិទ្យាល័យធុរកិច្ច និងសេដ្ឋកិច្ចអន្តរជាតិ
សកលវិទ្យាល័យព្រៃឈើក្រុងប៉េកាំង
សភាវិទ្យាសាស្ត្រកសិកម្មត្រូពិកនៃប្រទេសចិន
វិទ្យាស្ថានការទទួលខុសត្រូវសង្គមនៃសារជីវកម្មរ៉ុងជី ក្រុងប៉េកាំង
សភាព្រៃឈើនៃប្រទេសចិន
វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ និងព័ត៌មានព្រៃឈើ (RIFPI), សភាព្រៃឈើចិន
វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចបរទេសនៃគណៈកម្មការអភិវឌ្ឍជាតិនិងកែទម្រង់
មជ្ឈមណ្ឌលសម្រាប់ពាណិជ្ជកម្មអន្តរជាតិផលិតផលព្រៃឈើនៃរដ្ឋបាលព្រៃឈើរដ្ឋ
មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិនៃក្រសួងការពារបរិស្ថាននៃសាធារណរដ្ឋប្រជាមានិតចិន
មជ្ឈមណ្ឌលជាតិពិសោធន៍កៅស៊ូសំបកកង់
វិទ្យាស្ថានសិក្សាអន្តរជាតិចិន
មជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ចជនបទ។ ក្រសួងកសិកម្មនៃសាធារណរដ្ឋប្រជាមានិតចិន
វិទ្យាស្ថានអន្តរជាតិអភិវឌ្ឍន៍ដោយចីរភាព
មជ្ឈមណ្ឌលហ្វ្រីដ្សណូវសេន
វិទ្យាស្ថានធនធានសង្គម
ក្រុមសិក្សាស្រាវជ្រាវកៅស៊ូអន្តរជាតិ
សកលវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាគីនដាវ

សមាគមឧស្សាហកម្ម
ក្រុមប្រឹក្សាជាតិវាយនភណ្ឌនិងសម្ភារៈតែងកាយនៃប្រទេសចិន
សមាគមជាតិកៅស៊ូធម្មជាតិ
សភាពាណិជ្ជកម្មចិនសម្រាប់ការនាំចូល និងនាំចេញចំណីអាហារ ផលិតផលក្នុងស្រុកនិងអនុផលពីសត្វ
សមាគមចិនសម្រាប់ការជម្រុញកិច្ចសហប្រតិបត្តិការកសិកម្មអន្តរជាតិ
គណៈកម្មាធិការចិនសម្រាប់សារជីវកម្មពលរដ្ឋ

សហគ្រាស/វិទ្យាស្ថានពិគ្រោះយោបល់
ក្រុមឧស្សាហកម្មជាតិហៃណានកៅស៊ូធម្មជាតិនៃប្រទេសចិន កូ អឹលធីឌី
សារជីវកម្មអន្តរជាតិស៊ីណូចេម
ក្រុមហ៊ុនសាធារណៈកសិ-ឧស្សាហកម្មស្រ៊ីត្រាង លីមីធីត
ក្រុមមីធីលីន
វិទ្យាស្ថានស្រាវជ្រាវសំបកកង់ក្រុងសាងហៃនៃក្រុមជាប់បលខ៣ កូអឹលធីឌី
សារជីវកម្មសំបកកង់និងកៅស៊ូជាតិប្រទេសចិន
សហគ្រាសផលិតយានយន្តលេខ ២នៅជាគីន
ក្រុមមីធីលីន កូអឹលធីឌី
សហគ្រាសអភិវឌ្ឍន៍បច្ចេកវិទ្យារ៉ាងហ៊ុយ យីហ្វាងនៃក្រុងប៉េកាំង កូអឹលធីឌី
សហគ្រាសអភិវឌ្ឍន៍ហ្សាវឡាង ជីនរុន កូ អឹលធីឌី
មជ្ឈមណ្ឌលបច្ចេកវិទ្យាសំបកកង់ លីងឡុងនៅប៉េកាំង
ស៊ីនតាវ
SGS
អេវើប្រាយ ហ្វូឈឺរ កូ អឹលធីឌី
ក្រុមទីប្រឹក្សាវិនិយោគគីហ្វេង នៃក្រុងប៉េងកាំង កូ អឹលធីឌី

អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍, OECD
កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ, UNDP
មូលនិធិពិភពលោកសម្រាប់អភិរក្សធម្មជាតិ ឬ មូលនិធិសត្វព្រៃពិភពលោក, WWF
អុកស្វាម
ក្រុមប្រឹក្សាថែរក្សាព្រៃឈើ, FSC

ក្លូបល វីតណេស
វិទ្យាស្ថានធនធានពិភពលោក, WRI
សមាគមអភិរក្សសត្វព្រៃ, WCS
មូលនិធិហេនរិច បូល
ផៃណា ឌីយ៉ាឡូក
អង្គការពលកម្មអន្តរជាតិ, ILO
និន្នាការព្រៃឈើ
ក្រុមប្រឹក្សាការពារធនធានជាតិ, NRDC
សម្ព័ន្ធភាពព្រៃស្រោង, RA
កិច្ចផ្តួចផ្តើមរាយការណ៍ពិភពលោក, GRI
ក្រុមអ្នកច្បាប់វិស្ថ
វិទ្យាស្ថានហាតឡែន
ក្រុមប្រឹក្សាជនភៀសខ្លួនន័រវេស
វេទិកាអង្គការមិនមែនរដ្ឋាភិបាលដើម្បីកម្ពុជា
វិទ្យាស្ថានកម្ពុជាដើម្បីសហប្រតិបត្តិការនិងសន្តិភាព
គម្រោងម៉ូសាអេកនៃវិទ្យាស្ថានដើម្បីសិក្សាសង្គមនៅសកលវិទ្យាល័យអ៊ីរ៉ាស្មុសនៅទីក្រុងឡាអេ

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

*The NGO Forum on Cambodia*

ធ្វើការរួមគ្នាដើម្បីការពារប្រសើរឡើង

*Working Together for Positive Change*

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ត្រូវបានបង្កើតឡើងនៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលធ្វើយុទ្ធនាការដើម្បីបញ្ចប់ការដាក់ទណ្ឌកម្មជំនួយលើប្រទេសកម្ពុជា។ ក្រោយពេលស្ដាបនាឡើងវិញនូវជំនួយអភិវឌ្ឍន៍ក្នុងឆ្នាំ១៩៩៣ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានចាប់ផ្ដើមធ្វើការលើបញ្ហាផ្សេងៗជាច្រើន ដូចជាការហាមឃាត់គ្រាប់មីនជាអន្តរជាតិ ការបង្កើតសាលាក្ដីអចិន្ត្រៃយ៍មួយសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបារម្ភអំពីផលប៉ះពាល់នៃជំនួយអភិវឌ្ឍន៍។ បច្ចុប្បន្ន វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា មានអង្គការសមាជិកភាពចំនួន៩៦ និង ៤៥០អង្គការសមាជិកបណ្ដាញ។

បេសសកម្មរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ធ្វើការសម្របសម្រួល និងពង្រឹងសមត្ថភាពសមាជិកភាព សមាជិកបណ្ដាញនៃអង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀតចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចសន្ទនាគោលនយោបាយ និងធ្វើការតស៊ូមតិដើម្បីធានាឱ្យមានការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន សមធម៌ និងចីរភាពនៅកម្ពុជា។


អាសយដ្ឋានអគារលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន
ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ ប្រទេសកម្ពុជា

Tel: (855-23) 214 429
Fax: (855-23) 994 063
E-mail: ngoforum@ngoforum.org.kh
https://www.facebook.com/ngoforumoncambodia
https://twitter.com/thengoforum
https://www.youtube.com/user/ngofoncambodia
Website: http://www.ngoforum.org.kh